សាកលវិទ្យាល័យភ្នំពេញ

មហាវិទ្យាល័យប្រវត្តិវិទ្យា

ឯកសារជំនួយស្មារតី

សំរាប់ការសិក្សា

# ប្រវត្តិសាស្ត្រកម្ពុជា

## សម័យ...

នគរភ្នំ — ចេនឡា

អង្គរ - ក្រោយអង្គរ

( សាសនា . ស្ថាប័ដសិល្បៈ
សិលាចារឹក . ជីវភាពសង្គម )

ធិន . សំណាង

ប្រើប្រាស់ផ្ទៃក្នុង...

បណ្ណាល័យ BUDDHIST INSTITUTE LIBRARY
៥១០.
៤២
-133
www.budinst.gov.kh www.elibraryofcambodia.org

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ** និង **មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

៥១០.៧៥

សាកលវិទ្យាល័យភ្នំពេញ
មហាវិទ្យាល័យប្រវត្តិវិទ្យា

ឯកសារជំនួយមេរៀន
សំរាប់ការសិក្សា

# ប្រវត្តិសាស្ត្រកម្ពុជា

សម័យ...

នគរភ្នំ — ចេនឡា
មុនអង្គរ . ក្រោយបុរេ-អង្គរ

( សាសនា . ស្ថាបត្យសិល្បៈ
សិលាចារឹក . ជីវភាពសង្គម )

LIBRARY
៣៦១៣/៩៨

ទិន . សំណាង

133

ប្រើប្រាស់ផ្ទៃក្នុង..

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# អារម្ភកថា

បើចង់ក្ដាប់បាននូវដំណាក់កាលនានា ដែលបុព្វបុរសយើងបានឆ្លងកាត់ , នូវប្រពៃណីជាតិដ៏ល្អ , នូវវប្បធម៌ជាតិដ៏សំបូរណ៌រុងរឿង និងការវិវត្តរបស់សង្គមយើងតាំងពីបុរាណកាលតរៀងមក ចាំបាច់ត្រូវសិក្សាប្រវត្តិសាស្ត្រជាតិ ។ ការសិក្សាប្រវត្តិសាស្ត្រជាតិ នាំអោយយើងស្គាល់ មិនត្រឹមតែអតីតកាលរបស់ជាតិយើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយយើងអោយយល់អំពីបច្ចុប្បន្នកាលទៀតផង ។

របបប្រល័យពូជសាសន៍ បានបំផ្លិចបំផ្លាញឯកសារដែលជាស្នាដៃស្រាវជ្រាវរបស់អ្នកប្រាជ្ញខ្មែរយើងពីសម័យមុនសឹងតែទាំងអស់ នាំអោយយុវជនជំនាន់ក្រោយ មានការលំបាកយ៉ាងខ្លាំង ក្នុងការសិក្សាស្វែងយល់អំពីអតីតកាលនៃប្រទេសរបស់ខ្លួន ។

សៀវភៅដ៏តូចនេះ ត្រូវបានរៀបរៀងតាមលំនាំនៃស្នាដៃស្រាវជ្រាវរបស់ព្រះវិរិយបណ្ឌិត ប៉ាង - ខាត់ ។ យើងខ្ញុំបានសំរួលពាក្យពេចន៍ និង ដកស្រង់យកតែចំនុចណាដែលយើងយល់ឃើញថាសមស្រប និងមានប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវរបស់គរុនិស្សិតយើង ដើម្បីអោយយល់កាន់តែច្បាស់អំពីអតីតកាល នៃប្រទេសយើងថែមទៀត ។ យើងពុំមានបំណងចង់ពង្រីកតួនាទី និង ឥទ្ធិពលនៃសាសនា ឬ បុគ្គលណាមួយឡើយ ។ បើមិនរៀបរៀងចងក្រងឡើងវិញទេ ស្នាដៃស្រាវជ្រាវដ៏មានតំលៃនេះនឹងកប់បាត់ស្រមោលសូន្យឈឹងជាក់ជាពុំខានឡើយ ។

ភ្នំពេញ , ថ្ងៃទី ២៣ វិច្ឆិកា ១៩៨៧

អ្នករៀបរៀង : សឹម - សំណាង

សាស្ត្រាចារ្យ : ប្រវត្តិវិទ្យា

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# អំណរគុណ

✾✾✾

យើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ :-

១- សមមិត្ត ប៉ែន ណាវុធ រដ្ឋមន្ត្រីក្រសួងអប់រំ

២- សមមិត្ត វ៉ា ស៊ឹមសំរិទ្ធ នាយករងសាលាគរុវិជ្ជាជាន់ខ្ពស់

៣- សមមិត្ត ទេព ឮរ៉ុម នាយករងសាលាគរុវិជ្ជាជាន់ខ្ពស់

ដែលបានជួយពិនិត្យ និង រួមចំណែកផ្តល់មតិល្អ ៗ ធ្វើអោយខ្លឹមសារ នៃការស្រាវជ្រាវនេះកាន់តែប្រសើរឡើងថែមទៀត ។

អ្នករៀបរៀង

✾✾✾✾✾✾✾✾✾

www.budinst.gov.kh www.elibraryofcambodia.org

# ប្រវត្តិពុទ្ធសាសនា នៅប្រទេសកម្ពុជា

១- ប្រភពផ្សាយពុទ្ធសាសនាចូលមកប្រទេសកម្ពុជា :

ក្រោយពុទ្ធបរិនិព្វានទៅប្រមាណជា ២១៨ ឆ្នាំ មានស្តេចមួយអង្គនាមព្រះបាទធម្មាសោកមហារាជ បានឡើងសោយរាជ្យក្នុងរាជធានីបាតលិបុត្ត ដែនមគធរដ្ឋ ។ ស្តេចអង្គនេះប្រកបដោយឫទ្ធានុភាពច្រើន បានផ្សាយតេជានុភាពទូទាំងប្រទេសឥណ្ឌា ។ ទ្រង់បានចូលកាន់ពុទ្ធសាសនា ហើយបានជួយឧបត្ថម្ភក្នុងការធ្វើតតិយសង្គាយនា ព.ស ២៣៥ ។ យើងបានដឹងតាមប្រភពកោះលង្កា ថា ក្រោយពេលធ្វើតតិយសង្គាយនា ព្រះមោគ្គលិបុត្តតិស្សត្ថេរ បានបញ្ជូនព្រះសោណត្ថេរ "១" និងព្រះឧត្តរត្ថេរ មកកាន់សុវណ្ណភូមិ ក្រោមការឧបត្ថម្ភនៃព្រះបាទធម្មាសោកមហារាជ ។

២- សម័យនគរភ្នំ :

-ពីពុទ្ធសតវត្សទី ៦ ទៅ ទី ១១ " ព.ស ៥៤៣ - ១០៩៣ "

ពីគ្រិស្តសតវត្សទី ១ ទៅ ទី ៦ " គ.ស ទី ១ - ៥៥០ "

បើយើងយកគម្ពីរមហាវង្ស ជាប្រភពកោះសិរីលង្កាមកជាសក្ខីភាព យើងត្រូវនិយាយថា ពុទ្ធសាសនាបានចូលមកប្រទេសកម្ពុជា យ៉ាងតិចពីពុទ្ធសតវត្សទី ៣ " ព.ស ២៣៥ " មុនគ្រិស្តសករាជ ៣០៨ឆ្នាំ ព្រោះថែនដីកម្ពុជា យើងតាំងនៅក្នុងមណ្ឌលសុវណ្ណភូមិខាងបូព៌ទិស ឬ អាស៊ីអាគ្នេយ៍ ដែលប្រភពឯកសារទាំងឡាយពុំបានកំនត់អោយច្បាស់លាស់ថា ពុទ្ធសាសនាចូលមកក្នុងរដ្ឋកាលណា ? ព្រះថេរៈអង្គណា ឬ សោណកណា បាននាំមកប្រតិស្ឋានមុនដំបូង [១] ? ដំណឹងនេះនៅក្នុងភាពងងឹតទាំងអស់ ព្រោះហេតុការណ៍ទាំងឡាយ មិនថាតែក្នុងកម្ពុជាទេ សូម្បីក្នុងភូមិភាគដទៃ ដែលមាននៅក្នុងសុវណ្ណភូមិទាំងប៉ុន្មាន កាលពីមុនគ្រិស្តសករាជ ក៏ច្រើនតែពុំ

១ - បុរាណកថេរ .

www.budinst.gov.kh www.elibraryofcambodia.org

ស្ងួនមានប្រវត្តិអ្វីជាភស្តុតាង ម្ល៉ោះហើយគេចាត់ទុកសម័យនេះថា ជាសម័យមុនប្រវត្តិសាស្ត្រតែម្តង ។

កាលនោះ "ពីគ្រិស្តសតវត្សទី ១ ទៅទី ៦" ប្រទេសកម្ពុជាយើងមានឈ្មោះថា "នគរភ្នំ" "១" ដែលចិនហៅថា ហ្វូណន (Founan) រាជធានីហៅថា ទូ មូ ត្រូវនឹងពាក្យខ្មែរបុរាណថា "ទំមាក់ ត្រមាក់ ប្រែថា "អ្នកប្រាញ់" ស្របនឹងសិលាចារឹកជាភាសាខ្មែរថា "កុរុងព្នំ ឬ វ្រះវ្នំ" ជាសំស្ក្រឹតថា "បវ៌តភូបាល" ប្រែថា "ស្តេចភ្នំ" ឯរាជធានីហៅថា "វ្យាធបុរៈ បុរីអ្នកប្រាញ់" ជាទីក្រុងតាំងនៅតំបន់ បាភ្នំ (ទំនងជានៅភ្នំខ្សាច់ស ក្នុងខេត្តព្រៃវែងបច្ចុប្បន្ននេះឯង ) ព្រោះនៅកន្លែងនេះមានបុរាណដ្ឋាន និង បុរាណវត្ថុ រូបសម័យនគរភ្នំច្រើនណាស់ ព្រមទាំងមានសិលាចារឹកមួយនៅភ្នំក្តុបក្រិត "២" នៅឯជើងភ្នំ ពីគ្រិស្តសតវត្សទី ១០ និយាយថា បានលាងទេវរូបព្រះឥសូរមួយហៅថា "អម្រិតវ្យាធបុរេ-ស្វរៈ" ដាក់ក្នុងទីនោះផង ។ ពង្សាវតារក្នុងសម័យព្រេងនាយទាំងប៉ុន្មានបាត់បង់អស់ទៅតាមកាលវេលា នៅមានសល់តែសិលាចារឹកដែលនៅវ៉ាត់ កាញ៉ូ "៣" ខេត្តព្រៃត្រាង ១ (វៀតណាម) នៅអ្នកតាដំបងដែក "៤" ខេត្តតាកែវ ១ នៅប្រាសាទប្រាំល្វែង កូសាំងស៊ីន ១ និងនៅទន្លេបាទី ខេត្តតាកែវមួយ ។ សិលាចារឹកទាំងនេះ ខ្លះនិយាយពីស្តេចគោរពសាសនាព្រាហ្មណ៍ ខ្លះនិយាយពីស្តេចគោរពពុទ្ធសាសនា ។ ក្រៅពីនេះ យើងមានប្រភពចិន "៥" ជាឯកសារដែលលោក ប៉ូល-ប៉េលីយោ (Paul Pelliot) បានប្រែចេញពីពង្សាវតារចិនថែមទៀត

---

"១" G-Coedès, Histoire ancienne des Etats hindouisés d'Extrême-Orient, P. 43-44.

"២" P. Dupont, la statuaire préangkorienne ASCONA, P. 17

"៣" Barth - Bergaigne, ISCC, N° XX, 191.

"៤" G- Coedès, BEFEO XVI, 484.

"៥"

ឯកសារចិននិយាយថា " ខ្មែរយើងបានកសាងខ្លួនជាប្រជាជាតិមួយ មានរូបរាងកើតឡើងក្នុងពិភពលោកតាំងពីគ្រិស្តសតវត្សរ៍ទី ១ " ។ តែលោកហ្វែរ៉ង់ "១" (Ferrand) ថា " នៅប្រទេសនគរភ្នំនេះ មានជនជាតិឥណ្ឌា បាននាំយកវប្បធម៌ខ្លួនមកផ្សាយតាំងតែពីពុទ្ធសតវត្សរ៍ទី ៣ គឺតាំងពីមុនគ្រិស្តសករាជ ៣០០ឆ្នាំម្ល៉េះ " ។ មានប្រភពចិន "២" ខ្លះនិយាយថា " មានការទាក់ទងរវាងប្រទេសកម្ពុជា និង ចិន តាំងពីមុនគ្រិស្តសករាជច្រើនរយឆ្នាំ តែដែលអ្នកប្រាជ្ញប្រវត្តិសាស្ត្រចាត់ទុកជាផ្លូវការនោះគឺ ចាប់ពីគ្រិស្តសតវត្សរ៍ទី ៣ រៀងរហូតមក ។ រាជទូតចិនដែលមកប្រទេសយើងជាបឋម គឺនៅមុន គ.ស ៣២១ បន្តិច ហើយមានពីគ.ស២៤៣ មករហូតដល់គ.ស ៤៣៤ ។ លោកបានចែកជាសម័យដូចតទៅនេះ :-

១- សម័យមុនគ្រិស្តសករាជ

២- សម័យសាន់-គួ-ចេ ( San-Kouo-Tche ) គ.ស ២២០-២៨០

៣- សម័យពង្សាវតារទ្សិន ( Tsin ) គ.ស ២៦៥-៤១៩

៤- សម័យពង្សាវតារសុង ( Song ) គ.ស ៤២០-៤៧៨

៥- សម័យពង្សាវតារទ្សី ( Tsi ) ខាងត្បូង គ.ស ៤៧៩-៥០១

៦- សម័យពង្សាវតារលាង ( Leang ) គ.ស ៥០២-៥៥៦ ។ល។

សម័យសាន់-គួ-ចេ រជ្ជកាលស្តេចចិននាម វូ (Wou) គ.ស២២០ ដល់ ២៨០ បានបញ្ជូន កាំង-ថៃ ( Kang - Thai ) និង ជូ-យីង ( Tchou Ying ) ជាបឋមទូតមកកាន់ប្រទេសយើងនៅដើមគ្រិស្តសតវត្សរ៍ទី ៣ ។ បើយើងប្រមូលឯកសារទាំងនោះមករួមគ្នា យើងនឹងអាចដឹងបានដូចតទៅនេះ :-

---

"១" G. Ferrand, le Kouen - Louen, J.A, P. 549

"២" P.Pelliot, le Founan ( tirage à part ), P.58-59.

www.budinst.gov.kh www.elibraryofcambodia.org

" នាជាណាចក្រនគរភ្នំ តាំងនៅនឹងឆ្នេរឈូងសមុទ្រមួយផង ខាងកើតខ្ទល់នឹងប្រទេស លិន យី ( ប្រទេសចាម្ប៉ា ) ចំងាយពីប្រទេសលិន យី មក ៦០០០លី , ខាងលិចទៅទល់នឹងប្រទេសឥណ្ឌា និងរាជាណាចក្រគិន លិន " ព្រំដែនមាស " ទំហំប្រទេសចំនួន ៣០០០លី ។ មានក្រុងច្រើនសុទ្ធសឹងព័ទ្ធជុំវិញដោយកំពែង មានប្រាសាទរាជដ្ឋានប្រកបដោយជាន់ មានគេហដ្ឋាន ។ លើដីមានព្រៃព្រឹក្សា គ្រឿងទេស មានសត្វទឹក សត្វគោក បក្សី ក្ងោក ចចាត សេកពណ៌ , ក្នុងដីមាន មាស ស្ពាន់ សំណ ដែក ។ មិនមានអ្វីខ្វះខាតទេ មានសម្បត្តិប្រទេសដែលរកបានដោយកំរ ដូចជា មាស ពេជ្រ និលចិន្តា កែវ ជាដើម ។ មានដើមអំពៅ ក្រចឹម ក្រូចពោធិ៍សាត់ ដើមល្វា ដើមដូង ។ ប្រជាជន សម្បុរខ្មៅ សក់រួញ ប្រជុំភូមិមួយៗមានអណ្តូងមួយ រកស៊ីធ្វើស្រែចំការ , ចេះត្បាញរវៃ អំបោះ សូត្រ , ចេះសិល្បៈឆ្លាក់ក្បាច់រចនា , ធ្វើចិញ្ចៀន កងកណ្ដិ ខ្សែកណ្ដិ ខ្សែដៃ កងជើង មានចានប្រាក់ប្រើប្រាស់ យកមាសប្រាក់គជ គ្រឿងក្រអូបបង់ពន្ធអាករ មានក្បួនច្បាប់ មានមន្ទីរឯកសារ អក្សរសរសេរតាមអក្សរឥណ្ឌា ទំនៀមការកូនចៅ ឬ បុណ្យខ្មោចដូចនៅប្រទេស លិន យី ដែរ ប្រជាជនកាន់សាសនាព្រាហ្មណ៍ គោរពព្រះមហេស្វរៈ កាន់ពុទ្ធសាសនា គេធ្វើទេវរូប ពីសំរិទ្ធ ពីថ្ម បើមុខពីរមានដៃបួន បើមុខបួនមានដៃប្រាំបី ដៃមួយៗ កាន់គ្រឿងឧបករណ៍ផ្សេងៗ ឬកាន់ព្រះអាទិត្យ ព្រះចន្ទ ។ ទំនៀមកាន់ទុក្ខខ្មោច ត្រូវកោរពុកមាត់ កោរសក់ ។ ទំនៀមទុកដាក់សពមានបួនយ៉ាង គឺកប់ក្នុងដី , ចោលក្នុងទីព្រៃស្មសានអោយបក្សីស៊ី , ទំលាក់ចោលក្នុងទឹក , ដុត ។ មានពាណិជលក់ដូរគ្រឿងទេស , មានប្រាក់ , សំពត់ព្រៃ ។ មានពាណិជពីប្រទេសឆ្ងាយទៅមកលក់ដូរ ។ ប្រទេសសមន្តរាជ មាននាម៉ឺនខ្ទង់ ... ទាំងអស់នោះឈ្មោះ គុរង់លុអង់ ។

ប្រទេសនគរភ្នំនិងចិន ពី ទាំងពីរនេះ មានការទាក់ទងគ្នាតាមផ្លូវជើងទឹក ជើងគោក ហើយជួយគ្នាទៅវិញទៅមក ។ ប្រទេសនគរភ្នំទាក់ទងរហូតទៅដល់ប្រទេសឥណ្ឌា ។ មានពាណិជឥណ្ឌាម្នាក់ឈ្មោះ កៀ-សាង-លី ( Kia -Siang- Li) បានមកលក់ដូរដល់ប្រទេសនគរភ្នំ ប្រហែលជាក្នុងកណ្តាលគ្រិស្តសតវត្សទី ២ ហើយសរសើរថាប្រទេសនេះជាទីវិនរុងរឿង " ។

ហេតុនេះបានជា ក្នុងរជ្ជកាលស្តេច ចិន ឈ្មោះ វូ ( Wou ) មានបរិយាយថា ព្រះបាទ ហ្វាន់ចាន់ ប្រទេសនគរភ្នំ បានបញ្ជូនរាជទូតជាកៀត្រូមួយអង្គ ឈ្មោះ ស៊ូ - វូ ( Sou - Wou ) អោយទៅកាន់ប្រទេសឥណ្ឌា ( ប្រហែលជានៅចុងគ្រិស្តសតវត្សទី២ ) "១" ចុះសមុទ្រទៅកំពង់ តេវ៉ូ - គីវ - លី គឺកំពង់តក្កោលៈ "២" សព្វថ្ងៃនេះហៅថា តាគួប៉ា ទៅប្រជាយ ម៉ាឡាយូ ដែលជាដែនដីខ្មែរខាងបច្ចិមទិសទល់សមុទ្រឥណ្ឌា ដើរសំពៅលសៀវតាមឈូងសមុទ្រ កាត់ស្រុកជា ច្រើន មួយឆ្នាំបានដល់ទន្លេឥណ្ឌា ( ទន្លេគង្គា ) ហើយធ្វើដំណើរតាមទូកទៅទៀត ចំនួន៧០០០លី បានទៅដល់រាជធានីស្តេច ឥណ្ឌា ( Le Founan , P.Pelliot ) ។

លោកស៊ី-ទេវ្រី យល់ថា ព្រះរាជានេះ ( ឥណ្ឌា )ជាវង្សមុរុណ្ឌៈ ។ ស្តេចអង្គនេះស្ញើចណាស់ លាន់ព្រះឱស្ឋថា ឱហ្ន៎ នៅត្រើយសមុទ្រម្ខាងមានមនុស្សដែរតើ ! ហើយត្រាស់បង្គាប់អោយនាំរាជទូតខ្មែរដើរមើលប្រទេស ឥណ្ឌា ។ ដល់ពេលត្រឡប់មកវិញ ស្តេចឥណ្ឌាបានបញ្ជូនរាជទូតម្នាក់ឈ្មោះ ចិន-សុង អោយមកជាមួយរាជទូតខ្មែរផង ព្រមទាំងនាំយកជង្វាយ មានសេះនៃប្រទេស យូចេ ៤ ( សេះសិន្ធពដែលមាននៅតាម

---

"១" P.Pelliot, le Founan ( tirage à part) , P.30

"២" តាំងនៅត្រង់ទីក្រុង តាគួប៉ា ( Takuapa )ខាងលិចប្រជាយក្រា ( Kra )ចិន ហៅថា តេវ៉ូ-គីវ-លី( T'eou-Kiu-li )

www.budinst.gov.kh www.elibraryofcambodia.org

ផងទន្លេសិទ្ធ) ជាដើម មកថ្វាយស្តេចខ្មែរ ។ ទាំងទៅទាំងមក ឆ្នាំ បានផលមកប្រទេសនគរភ្នំវិញ គឺកាលនោះហើយដែលស្តេចក្រុងចិន នាមវូ បានបញ្ជូន កាំង-ទាំ និង ជូ-យីង ជាបេសកទូតចិន អោយមកប្រទេសនគរភ្នំ ក្នុងរជ្ជកាលព្រះបាទ ហ្វាន់-ស៊ុន ទំនងជាក្នុងគ្រិស្តសករាជ២២៥-២៣០ បានជួបរាជទូត ឥណ្ឌ កិន-សុង ហើយសាកសួរពីទំនៀមទំលាប់និងស្ថានភាពប្រទេសឥណ្ឌា ផង ។

ប្រភពឯកសារចិន អានឃើញថាស្តេចនៅប្រទេសនគរភ្នំជាច្រើនអង្គ ។ មានស្តេចមួយអង្គ ប្រហែលជានៅចុងគ្រិស្តសតវត្សទី ២ មាននាមថា ហ្វាន់ ម៉ុន ឬ ហ្វាន់-ចេ-ម៉ុន (ស្រីមារៈ) ជាស្តេចកាន់ពុទ្ធសាសនា មានកិត្យានុភាពល្បីល្បាញ ។ ប្រភពចិនរៀបរាប់ថា នៅនគរភ្នំមានអាធិបតីជាស្ត្រីសោយរាជ្យជាទំនៀម ព្រះរាជាធិនីមួយអង្គព្រះនាម លៀវ-យី (លីវ-អី)(Feuille de saule)(សោមា) មានរូបឆោមល្អ ។ ពេលមានព្រាហ្មណ៍ម្នាក់ឈ្មោះ ហ៊ុន-ទៀន បានធ្នូសមុទ្រដែលទេពតាប្រទានក៏ចុះសំពៅមកកាន់ប្រទេសនគរភ្នំ ។ ព្រះនាងលីវ-យី លើកទ័ពទៅច្បាំងនឹងព្រាហ្មណ៍ ហ៊ុន-ទៀន នោះតែត្រូវចាញ់ ក៏ព្រមទទួលយកជាស្វាមី ។ ព្រះបាទ ហ៊ុន-ទៀន និង នាងលីវ-យីនេះ ជាបឋមក្សត្រ ។ រឿងព្រះបាទហ៊ុន-ទៀន និងនាងលីវ-យី តាមឯកសារចិននេះ ស្រដៀងគ្នានឹងសិលាចារឹកនៅ មី សឺ ន "១" (Myson) ក្នុងគ.ស ៦៥៨ និយាយថា ព្រះបាទកៅណ្ឌិន្យ បានប្រតិស្ឋានលំពែង ដែលទ្រង់បានពីអស្វត្ថាម៉ន ជាបុត្រទ្រោណៈ មកដាក់ស្ទុកនៅភវបុរៈ បានព្រះនាងនាគីសោមា ជាអគ្គមហេសី ហើយតាំងជារាជវង្សដើមនៃប្រទេសនេះឡើង ។ សិលាចារឹកនៅ

---------------------------------------------------- ./.

www.budinst.gov.kh www.elibraryofcambodia.org

ប្រាសាទបក្សីចាំក្រុង "១" ពីគ.ស ៩៤៨ ចែងទុកថា ព្រះបាទរុទ្រវរ្ម័ន ជាស្តេចចុងក្រោយបង្អស់នៃសម័យនគរភ្នំ ជាស្តេចតវង្សមកពីព្រះបាទកៅ-ណ្ឌិន្យ និង នាងសោមា ។ ព្រះបាទ ហ៊ុន-ទៀន និង នាងលីវ-យី តាមឯកសារចិន គឺព្រះបាទកៅណ្ឌិន្យ និង នាងសោមា តាមសិលាចា-រឹកនៅ មីសឺន គឺព្រះថោង នាងនាគ ជាបឋមក្សត្ររបស់ខ្មែរ នៅនគរគោកធ្លកក្នុងពង្សាវតារយើងពិតប្រាកដ ។ ឯកសារចិននិយាយតមកទៀតថា ព្រះបាទ ហ៊ុន-ទៀន និងនាង លីវ-យី មានបុត្រមួយអង្គ ហើយទ្រង់តែងតាំងអោយត្រួតត្រាប្រទេសសមន្តរាជ ៧ នគរ ។ តមកមានស្តេចតំណវង្សមួយអង្គនាម ហួន-ប៉័ន-ហួង ( Houen-P'an-Houang ) លើកទ័ពទៅច្បាំងដណ្តើមយកសមន្តរាជទាំង ៧បាន ហើយបញ្ជូនរាជបុត្រ និងរាជនត្តា ព្រះអង្គទៅសោយរាជ្យជំនួសវិញ ។ ព្រះបាទ ហួន-ប៉័ន-ហួងនេះ ទិវង្គតក្នុងជន្មាយុ ៩០ឆ្នាំ ( គ្រិស្តសតវត្សទី ២ ) ។ បុត្រទី ២ របស់ស្តេចអង្គនេះ នាម ប៉័ន-ប៉័ន ឡើងសោយរាជ្យ ហើយទ្រង់តែងតាំងឧត្តមសេនីយម្នាក់ឈ្មោះ ហ្វាន់-ម៉័ន អោយសំរេចរាជការ-កិច្ច ។ បីឆ្នាំក្រោយមក ព្រះបាទ ប៉័ន-ប៉័ន ទ្រង់ទិវង្គតទៅទៀត ទើបអ្នកនគរលើកឧត្តមសេនីយ ហ្វាន់-ម៉័ន ជាស្តេចអោយឡើងសោយរាជ្យតមក ។ ព្រះបាទហ្វាន់-ម៉័ន ឬ ហ្វាន់-ចេ-ម៉័ន ( ស្រីមារៈ ) នេះជាស្តេចក្លាហាន ហើយវៀងវៃណាស់ ទ្រង់បានឡើងជាមហារាជា-ធិរាជ នៃប្រទេសនគរភ្នំ ។ ទ្រង់បានលើកទ័ពទៅវាយយកប្រទេសជិតខាងអោយចុះចូល ។ ប្រទេសជិតខាងសុទ្ធតែជាសមន្តរាជរបស់ព្រះអង្គ ។ ទ្រង់បានកសាងកងទ័ពជើងទឹកយ៉ាងធំ ហើយឆ្លងសមុទ្រ ទៅច្បាំងយកអាណាចក្រ ១០ មក ចំនុះព្រះអង្គទៀត ។ រាជាណាចក្រព្រះអង្គ

---

"១" G. Coedès , Inscription du Cambodge ,IV, P.96 .

ទឹកដំឡូលាយបានចំនួន ៥ ឬ ១០ ពាន់លីលើសដើម ។ ទ្រង់មានចំប៉ាំងលើក
ទ័ពទៅច្បាំងយករាជាណាចក្រ គិន - លិន ( Kin-Lin) "ព្រំដែន
មាស" ទៀតតែទ្រង់ព្រះយួន បើយទ្រង់ទីវង្គតក្នុងឱកាសនោះទៅ ។

មានសិលាចារឹកមួយ ចាស់បុរាណជាងគេបង្អស់នៅដែន
ឥណ្ឌូចិននេះ គឺសិលាចារឹក វ៉ូ - កាញ់ ហើយគេអាចប្រដូចអក្សរ
ទៅនឹងសិលាចារឹករុទ្រទាម័ន នៅគីរនារ ( Girnar ) ឬសាតករណិ
វាសិស្ឋីបុត្រ (Satakarni Vasisthiputra ) នៅកាន់ហេរី(Kanheri)
ក្បែរទន្លេគោទាវរី និងទន្លេក្រិស្នា នៃប្រទេស ឥណ្ឌាទក្ខិណទិស បាន ។
សិលាចារឹកនេះថ្លែងពីព្រះបាទ ស្រីមារៈ ( ហ្វាន់ - ជេ - ម៉ុន ) ថាទ្រង់
ជ្រះថ្លាចំពោះពុទ្ធសាសនា ប្រាកដដូចសិលាចារឹកជារាជប្រកាសរបស់
ព្រះបាទធម្មាសោកមហារាជ នៃប្រទេស ឥណ្ឌាដែរ ហើយគេបានរកឃើញ
នៅស្រុក វ៉ូ - កាញ់ ( Vo - Canh ) ខេត្តញ៉ាត្រាង ។ ដោយ
ហេតុតែគេបានរកឃើញនៅដែនដីចាម្បបុរាណ គេស្មានដោយភន្តច្រឡំ
ថាជាសិលាចារឹកប្រទេស ចាម្បទៅវិញ តែលោក លូហ្វីណូត៍ ( Louis-
Finot ) ពិចារណាឃើញថា ស្រុកវ៉ូ - កាញ់ កាលពីអតីតកាលមិន
មែនជាដែនដី ចាម្បទេ ប៉ុន្តែជាសមន្តរាជប្រទេសនគរភ្នំ ។ ភាគ
ខាងលើសិលាចារឹករលុបអក្សរអស់ហើយ មិនអាចមើលអោយដឹងសករាជបាន
ទេ តែគេស្គាល់បានដោយតួអក្សរដែលចាស់បុរាណពេក ស្ទើរតែមុនអក្សរ
ចារឹក ឥណ្ឌាខាងលើនេះខ្លះទៀតផង បានជាអ្នកប្រាជ្ញអក្សរបុរាណ ដូចជា
លោក បារថ៍ ( Barth ) និងលោកប៊ែរហ្គែញ (Bergaigne ) ទាយថា
អក្សរសិលាចារឹក វ៉ូ - កាញ់នេះ ទំនងជានៅក្នុងគ្រិស្តសតវត្សទី ៣
មានតែឡើងទៅដល់គ្រិស្តសតវត្សទី ២ ទៀតផង ។ សេចក្តីក្នុងសិលា
ចារឹកនោះថា ព្រះរាជាវង្សស្រីមារៈ បានត្រាស់បង្គាប់អោយចារឹក

www.budinst.gov.kh www.elibraryofcambodia.org

ទុក ដើម្បីជាអនុស្សាវរីយ៍ចំពោះព្រះបុទ្រស្រីមារៈថា រាជកុលៈ គឺបឋមវង្សជ្រះថ្លាចំពោះពុទ្ធសាសនា ទ្រង់ប្រកបដោយមេត្តាករុណា ហើយទ្រង់ត្រាស់បង្គាប់អោយបរិច្ចាគរាជទ្រព្យព្រះអង្គធ្វើជាទាន ទុកជាសាធារណប្រយោជន៍ ទីបញ្ចប់ទ្រង់ផ្តែផ្តាំទុកថា សូមព្រះរាជាសោយរាជ្យជាតំណតទៅអនាគតប្រតិបត្តិតាមរាជប្រកាសនេះ ដើម្បីជាប្រយោជន៍ធំដល់សត្វលោក ។ ខ្លឹមសារនៃសិលាចារឹកនេះ មានសេចក្តីប្រែសំរួល "១" ដូចតទៅ :-

" ... សេចក្តីករុណាចំពោះសព្វសត្វទាំងឡាយ...ប្រថមជ័យ... ថ្ងៃពេញបូណ៌មី ព្រះវររាជាទ្រង់បានប្រកាសក្នុងរាជសភាថា " ចូរប្រជាជនក្រេបផឹកនូវទឹកអម្រឹត ពោលគឺព្រះរាជបន្ទូលព្រះពុទ្ធ...ជាវង្សនៃព្រះបុទ្រស្រីមារៈ ទ្រង់បានជាកិត្តិយសនៃរាជវង្សស្រីមារៈ ទ្រង់បានប្រកាសក្នុងកណ្តាលជំនុំជន នូវព្រះរាជបន្ទូលសូរសីហនាទជាប្រយោជន៍ដល់ប្រជាជនទាំងឡាយ ទ្រង់ជាក្សត្រិយ៍ទាំងពីរដ៏ប្រសើរ ទ្រង់ប្រថាប់លើសិង្ហាសនៈ ( ព្រះរាជបល្លង្កស្វេតឆ័ត្រ ) ហើយទ្រង់ឃើញយល់នូវគតា គតិ គឺការអន្ទោលស្លាប់កើតនៃមនុស្សលោក ទើបត្រាស់ថា ". កាលបើកូនខ្ញុំក្តី បងប្អូនខ្ញុំក្តី មិនមែនអ្នកកន្ទៀតទេ បានសំរេចបំនងខ្លួនហើយ ( បានសោយរាជ្យតទៅ ? ) ( ខ្ញុំសូមអោយយក ) . សម្បត្តិខ្ញុំទាំងអស់ ប្រាក់មាសសង្ហារិមក្តី អសង្ហារិមក្តី ទៅប្រើជាវត្ថុបំរាប់ជាទីរីករាយ និងជាប្រយោជន៍ដល់សត្វលោកទាំងឡាយ ។ នេះជាសេចក្តីបញ្ជារបស់ខ្ញុំ ។ សូមព្រះរាជាទាំងឡាយនៅក្នុងអនាគតប្រតិបត្តិតាមបញ្ជាខ្ញុំនេះកុំបីខានៗ ហើយចូរប្រឹក្សាជាមួយសេនាកាមាត្យ ឈ្មោះ វីរ ... របស់ខ្ញុំ " ។

សិលាចារឹកនេះទុកជាសក្ខីភាព គឺជាឯកសារទៀងទាត់ បញ្ជាក់ថាប្រទេសនគរភ្នំកាន់ពុទ្ធសាសនា ។ ដូច្នេះយើងឃើញថា ក្នុងរជ្ជ-

---

"១" ប្រែសំរួលដោយព្រះវីរិយបណ្ឌិត ខ្វាង - ខាត់

កាលព្រះបាទស្រីមារៈ (គ្រិស្តសតវត្សទី ២) ពុទ្ធសាសនាបានផុះផាល់ក្នុងប្រទេសយើង តែបន្ទាប់ពីនោះមក ពុទ្ធសាសនាបាត់ដំណឹងអស់ជាច្រើនឆ្នាំ ។

ក្នុងគ្រិស្តសតវត្សទី ៥ (គ.ស ៤៧៩-៥០១) ពង្សាវតារចិន រាជវង្សតីខាងត្បូង "១" (Tsi méridionaux) មានសំណៅថា ស្តេចនៅនគរភ្នំកាន់ពុទ្ធសាសនា ។ ពង្សាវតារចិននេះថែងថា ស្តេចនគរភ្នំ ជារាជវង្ស កាវ-ចិន-ជូ (កៅណ្ឌិន្យ) នាម ចូ-យេ-ប៉ា-ម៉ូ (ជ័យវរ្ម័ន) គឺព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន ទ្រង់ឡើងសោយរាជ្យ ក្នុងពុ.ប. ១០២១ (គ.ស ៤៧៨) កាលដើមទ្រង់កាន់សាសនាព្រាហ្មណ៍ "២" គោរពព្រះមហេស្វរៈ (ព្រះឥសូរ) តែតមក ទ្រង់កាន់ពុទ្ធសាសនាវិញ ។ ក្នុងរជ្ជកាលស្តេចអង្គនេះ យើងបានដឹងថា ក្នុងព.ស ១០២៧ (គ.ស ៤៨៤) ទ្រង់បានបញ្ជូនភិក្ខុ ណា-កា-សៀង គឺភិក្ខុ នាគសេនៈ ជាតិឥណ្ឌា ជាបេសកជនទៅកាន់រាជសំណាក់ស្តេច ចិន វូ-ទី ទ្រង់បានផ្ញើគ្រឿងបណ្ណាការ ទៅថ្វាយស្តេចចិន គឺរូបឆ្លាក់រាជមាស ១ រូបវិទីធ្វើពីថ្មមច្ឆនី គ្រឹស្តាល ១ ស្លាបពីរធ្វើពីភ្លុក សំពត់២ផាប់ ចានតែកវពិទូរ្យពីរ ថាលដាក់ស្លាធ្វើពីក្រាល១ ។ កាលភិក្ខុនាគសេនៈត្រឡប់មកវិញ ស្តេចចិនបានសុំអោយលោកនាំគ្រឿងបណ្ណាការមកថ្វាយស្តេចនគរភ្នំវិញដែរ គឺសំពត់ក្រៅពណ៌បៃតង, ស្វាយ មានផ្កាពណ៌ខៀវ, លឿង មួយមុខៗ ៥ ផាប់ ។

ក្នុងព.ស ១០៤៦ (គ.ស ៥០៣) ព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន បានបញ្ជូនរាជទូតម្នាក់ទៅកាន់រាជសំណាក់ស្តេចចិនទៀត ។ ម្តងនេះ ទ្រង់បានអោយនាំគ្រឿងបណ្ណាការ សុទ្ធសឹងជាផលិតផលប្រទេស ទៅថ្វាយស្តេចចិន គឺពុទ្ធរូប ធ្វើពីផ្កាថ្មសមុទ្រ និង វត្ថុដទៃជាច្រើនទៀត ។

---

"១" P.Pelliot, le Founan, P.66

"២" L. Briggs, the ancient Khmer Empire, P.28

www.budinst.gov.kh www.elibraryofcambodia.org

ទ្រង់បានបញ្ជូនភិក្ខុខ្មែរពីរអង្គ ទៅប្រែព្រះត្រៃបិដកនៅប្រទេសចិន ។ ព្រះថេរទាំងពីរអង្គនេះ គង់នៅប្រទេសចិនក្នុងរវាងចុងគ្រិស្តសតវត្សទី ៥ និងដើមគ្រិស្តសតវត្សទី ៦ ។ ព្រះថេរមួយអង្គនាម សេង - គា - ប៉ូ - ឡូ គឺសង្ឃបាលោ កើតពីគ.ស ៤៦០ លោកចេះភាសាច្រើន ។ ស្តេចចិននាម វូ ក្នុងរាជវង្សលាង គ.ស ៥០៦ សុំនិមន្តលោកអោយជួយប្រែព្រះត្រៃបិដក លោកធ្វើការអស់ពេល ១៦ឆ្នាំ នៅហ្វូណន - ក្វាង ( Founan - Kouan ) ប្រែថា " ការិយាល័យប្រទេសនគរភ្នំ " ។ ព្រះសង្ឃបាលត្ថេរនេះសុគតក្នុងព.ស ១០៦៧ ( គ.ស ៥២៤ ) ។

ព្រះថេរៈមួយអង្គទៀតនាមថា ម៉ុន - តូ - ឡូ ( Man-to-lo ) ចន្ទ្រៈ ឬ ម៉ុន - តូ - ឡូ - សេង ( Man-to-lo-Sien ) មន្ទ្រសេនៈ ។ លោកនិមន្តទៅដល់រាជសំណាក់ស្តេចចិន នាម វូ ( រាជវង្សលាង ) ក្នុង ព.ស ១០៤៧ ( គ.ស ៥០៣ ) ហើយបានទទួលការអនុញ្ញាតអោយចូលធ្វើការប្រែព្រះត្រៃបិដកជាមួយព្រះមហាសង្ឃបាលត្ថេរ ។ សេចក្តីប្រែជាស្នាដៃព្រះថេរៈទាំងពីរអង្គនេះ មានជាប់ព្រះនាមនៅក្នុងត្រៃបិដកចិនរហូតមកដល់សព្វថ្ងៃ ។

ក្រៅពីប្រភពឯកសារចិន គេឃើញមានសិលាចារឹកពីរកន្លែងទៀត ពីសម័យនគរភ្នំ នៅចុងគ្រិស្តសតវត្សទី ៥ ដែលរំលឹកពីព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន ។ សិលាចារឹកមួយនៅប្រាសាទប្រាំល្វែង "១" ស្រុកទឹកខ្មៅ ( ខេត្តព្រែកឫស្សី ) រៀបរាប់ថា ព្រះរាជកុមារនាមគុណវរ្ម័ន រាជបុត្រនៃព្រះរាជា " ព្រះច័ន្ទនៃរាជវង្សកៅណ្ឌិន្យ " ទ្រង់ត្រាស់បង្គាប់អោយចារឹកទុកថា ទីនេះព្រះវរបិតាព្រះអង្គយកបានមកពី " ទីទឹកភក់ " ហើយតែងតាំងទ្រង់

---

"១" G.Coedès, BEFEO . XXXI , P.1 et suiv .

ក្រោយត្រួតត្រា ។ សិលាចារឹកមួយទៀត នៅអ្នកតាដំបងដែក (ខេត្តតាកែវ) ថ្លែងពីអគ្គមហេសីព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន នាមព្រះនាងកុល-ប្រភាវតី ទ្រង់មានប្រាជ្ញាចេញចាកលោក ហើយទ្រង់បានកសាងទេវា-ល័យដ៏កល់បដិមាព្រះវិស្ណុទ្វីពីមាត្រ ព្រមទាំងលំនៅសំរាប់ព្រាហ្មណ៍ និងស្រះ ។ ព្រះនាងកុលប្រភាវតី អង្គនេះជាព្រះរាជជននីរាជកុមារគុណវរ្ម័ន ។ ព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន ទ្រង់ទីវង្គតក្នុង ព.ស១០៥៧ (គ.ស ៥១៤) ។

ព្រះបាទរុទ្រវរ្ម័នទ្រង់ឡើងសោយរាជ្យតសន្តតិវង្សព្រះវរបិតាមក ។ ប្រភពចិន ពង្សាវតាររាជវង្ស លាំង និយាយតមកទៀតថា ព្រះបាទ លិវ-តូ-បាំ-ម៉ូ គឺរុទ្រវរ្ម័ន ជារាជបុត្រព្រះស្នំ មិនមែនជាអគ្គមហេសីទេ ទ្រង់ធ្វើគតមកុដរាជកុមារ (ប្រហែលជារាជកុមារគុណវរ្ម័ន ជាបុត្រអគ្គមហេសី ព្រះនាងកុលប្រភាវតី) ហើយឡើងសោយរាជ្យ ក្នុងគ.ស ៥១៤ គឺឆ្នាំដែលព្រះបិតាទ្រង់ទីវង្គត ។ លុះបានឡើងសោយរាជ្យហើយក៏ទ្រង់បញ្ជូនរាជទូតទៅកាន់ប្រទេសចិន ។ រាជទូតដែលទ្រង់បញ្ជូនក្នុងព.ស ១០៨២ (គ.ស ៥៣៩) បាននាំគ្រឿងបណ្ណាការព្រះអង្គ គឺសត្វរមាស ព្រមទាំងផលិតផលដទៃទៀតរបស់ប្រទេស។ រាជទូតនេះបានទូលស្ដេចចិនថា នៅប្រទេសនគរភ្នំ មានព្រះបរមសារី-រិកធាតុ គឺព្រះកេសមួយសរសៃប្រវែង ៣ ម៉ែត្រ ។ ក្រោយពីបានជ្រាបដំណឹងនេះ ស្ដេចចិនទ្រង់បញ្ជូនភិក្ខុ ឆ៊-ឃុន-ប៉ាវ អោយតាមរាជទូតខ្មែរមកដង្ហែព្រះបរមសារីរិកធាតុនោះយកថ្វាយទ្រង់ទៅ ។

ប្រភពចិននេះ មានសេចក្ដីស្របនឹងសិលាចារឹកខ្មែរនៅប្រាសាទតាព្រហ្មទន្លេបាទី ពីក្នុងពុទ្ធសតវត្សរ៍ទី ១១ (គ្រិស្តសតវត្សរ៍ទី ៦) ថា ព្រះបាទរុទ្រវរ្ម័ន ជារាជបុត្រ ព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន ទ្រង់

www.budinst.gov.kh www.elibraryofcambodia.org

ពុទ្ធសាសនាផែន, ហើយគេរាប់ព្រះបរមសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធ ដូចមានសេចក្ដីក្នុងសិលាចារឹកនោះថា "១":-

"ព្រះជិនស្រីទ្រង់ឈ្នះខ្មាំងសឹកសត្រូវ ពោលគឺកិលេស ព្រមទាំងវិទ្យា-សមា ទ្រង់ប្រកបដោយសម្បទាគ្រប់ប្រការ មានពោធិញ្ញាណឥតមើលទាល់ សល់ពីពាក្យអ្វីឡើយ មានព្រះទ័យប្រកបដោយករុណាចំពោះសព្វសត្វ មាន ព្រះយសធំទូលំទូលាយ ឥតមានមោះមន្ទិលអ្វីឡើយ ហើយផ្សាយទូទៅគ្រប់ ទិសានុទិស ។ ព្រះអង្គប្រោសប្រណ់សត្វដែលលិចលង់ក្នុងវាលវដ្ដសង្សារ គឺ ត្រៃភព ហើយបានដល់ត្រើយត្រាណសាន្តព្រះនិព្វានដ៏ឧត្ដម ឥតអ្វីប្រៀបបាន ឡើយ ។ ព្រះស្រីធាតុ ( គឺព្រះបរមសារីរិកធាតុ ) ព្រះអង្គដែលតែង តែផ្ដល់ប្រយោជន៍ដល់សព្វសត្វទាំងឡាយ ក៏នៅតែផ្ដល់ប្រយោជន៍ដល់សព្វសត្វ លុះរហូតមកដល់ឥឡូវនេះ ... ។ អំពើជាព្រះរាជកុសលដែលទ្រង់ ( ព្រះ បាទរុទ្រវរ្ម័ន ) បានបំពេញចំពោះព្រះធម៌ហើយ មិនមែនដើម្បីតែព្រះ រាជករណីយកិច្ចប៉ុណ្ណោះទេ គឺទ្រង់បំពេញដើម្បីអនុគ្រោះដល់លោកទាំងមូល ផង ។ ទ្រង់គោរពព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ...ទ្រង់បានតាំង ព្រះអង្គពេញជាឧបាសក ដែលឥតមានអំពើឃោរឃៅមក..."

សេចក្ដីប៉ុណ្ណោះនាំគោយយើងដឹងបានថា ក្នុងរជ្ជកាលព្រះបាទរុទ្រ-វរ្ម័ន ខ្មែរយើងមានព្រះបរមសារីរិកធាតុ គឺព្រះកេសមួយសរសៃ សំរាប់ ជាទីសក្ការបូជា តែត្រូវបាត់បង់ទៅវិញ ដោយស្ដេចចិន រាជវង្ស ធីវួនខាងត្បូង យកទៅ ។

រីឯទំនៀមគោរពព្រះបរមសារីរិកធាតុនេះ នៅប្រទេស ភូមា យើងបានដឹងថា ប្រវត្តិមួយនិយាយថា តបុស្ស និង ភល្លិកៈ ជា បឋមឧបាសកនោះជាជាតិមន បានព្រះកេសធាតុយកមកដាក់ទុកក្នុងសិង្គុត្តរ

---

១ G.Coedès, BEFEO. XXI, P. 6 et suiv

www.budinst.gov.kh www.elibraryofcambodia.org

ចេតិយ៍ ឬ ចេតិយ៍ ស្ទើតែគ្រប់ ។ ចុះព្រះបុទ្ធមសាសនាទិកធាតុរបស់យើង ដែលចែងទុកក្នុងឈ្លោហាទីកប្រាសាទអារាមប្ញ ។ ខន្ធហ្មទីនេះ តើបានមកពីណា ? ស្ទួនឮងទោយទឹកថា ព្រះបុទ្ធបាទទិកធាតុនេះ ជាមរតករបស់ តបុស្ស និង ភល្លិកៈ ទុកអោយជាតិខ្មែរ ព្រោះជាសាច់សន្តានជាមួយគ្នា ។

ក្នុងរជ្ជកាលព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន និង ព្រះបាទរុទ្រវរ្ម័ន ប្រទេសខ្មែរចម្រើនបានក្រៅរ្នកាលណា ។ ព្រះបាទរុទ្រវរ្ម័នប្រថែមជាព្រះអង្គគ្នប់ទាង គ.ស ១០៨៣ (ត.ស ៥៤០) ។

សម័យនោះក្តី រជ្ជកាលព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន និង ព្រះបាទរុទ្រវរ្ម័ន គោរព្រះពុទ្ធរូបថ្មីនអង្គ ធ្វើពីថ្ម ពីសំរិទ្ធ ឬ ពីឈើ ជាការចេញារបស់ខ្មែរ ដែលកែ...ណ៍ ក្បួ តទ្វារ មថុរា ឬ អជន្តា ។ ភ្នំដា "១" នៅអង្គរបុរី ជាមជ្ឈមណ្ឌលនៃការគលា៦បវិជ្ជា មានដើរ ឈ្មោះសំរូលប្រាញ ។ ចរិយា ដែលមានការចេញារតាមរបបភ្នំដា បាន ផ្ទ ពង្រាយទទៅពេញដែនដីនគរភ្នំ ទិសខាងកើតទៅដល់ភាគខាង ត្បូងនៃទៀតណាមកណ្តាល ។ នៅមឿងនៃយ៉ា (មឿងជយា សព្វ ការ...ក្រាយ) បានរូបទេវលោកិនេស្ទូរៈមួយ មានការចេញាដែលបភ្នំដា ។ លោក ស៊ីដែល ជារូបនេះ មានការចេញាដូចហរិហរៈ នៅអាស្រម មហាប្ញស៊ី ។

ព្រះពុទ្ធរូបដែលមានការចេញាដែលបភ្នំដា ចែកជាពីរបណ្តល គឺៈ-

១-នៅអង្គរបុរី និងទីជិតខាង មានព្រះពុទ្ធរូប ធ្វើពីថ្មចាស់ជាងគេបំផុត នៅអាស៊ីអគ្នេយ៍ ។

---

១ P. Dupont, Statuaires préankoriennes, P.66-67.

៧- នៅត្រពាំងវែង ខាងត្បូងខេត្តព្រះត្រពាំង ( ត្រាវិញ ),

ព្រះពុទ្ធរូបថ្ម នៅវត្តវាំលក "១" ចាស់ជាងគេ ការរចនាខ្មែរ បែបគុប្ត: ទ្រង់សណ្ឋិតឈរ គ្មានព្រះហស្ត នៅស្រុកព្រៃកប្បាស ខេត្តតាកែវ ក្នុងពុទ្ធសតវត្សទី ១០ (គ្រិស្តសតវត្សទី ៥) ។ ព្រះពុទ្ធរូបថ្មនៅត្រើង ទៀង ( ខេត្តលង់ហោ ) ទ្រង់សណ្ឋិតឈរ គ្មានព្រះហស្ត ក្នុងពុទ្ធសតវត្សទី ១០ ។ ព្រះពុទ្ធរូបឈើ "២" នៅទឹកខ្មៅ ( ខេត្តព្រែកឫស្សី ) ទ្រង់សណ្ឋិតឈរ គ្មានព្រះហស្ត ក្នុងពុទ្ធសតវត្សទី ១១( គ្រិស្តសតវត្សទី ៦ ) ។ ព្រះពុទ្ធរូបសំរិទ្ធ នៅវត្តឫះអាថ៌ (ខេត្តបាត់ដំបង) , ព្រះពុទ្ធរូបនៅទួលព្រះធាតុ (ខេត្តកំពង់ស្ពឺ) ទ្រង់សណ្ឋិតឈរ គ្មានព្រះហស្តដូចគ្នា ។ ព្រះពុទ្ធរូបនៅ សឹងថ ( ខេត្តព្រះត្រពាំង ) ព្រះពុទ្ធរូបនៅត្រពាំងវែង ( ខេត្តព្រះត្រពាំង ) ពីរអង្គនេះគង់ខាត់សមាធិ ។ មានព្រះពុទ្ធរូបនៅវត្តអាចារ្យចាស់ ( ខេត្តព្រះត្រពាំង ) មានព្រះពុទ្ធរូបនៅ កាប់ សាំងហ្សាក់( Cap Saint Jacques ) ។ ព្រះពុទ្ធរូបបីអង្គ "៣" មានចារឹកពុទ្ធភាសិតថា យេ ធម្មា... : មួយអង្គនៅវត្តផ្លេះ ជិតអង្គរបុរី( ខេត្តតាកែវ ), មួយអង្គនៅត្រពាំងវែង ( ខេត្តព្រះត្រ-ពាំង) និងមួយអង្គទៀតនៅទួលព្រះធាតុ ( ខេត្តកំពង់ស្ពឺ ) ។ ព្រះពុទ្ធរូបទាំងនេះជាការរចនាភ្នំដា អង្គរបុរី, បែបគមរាវតី ដូចព្រះពុទ្ធរូបនៅដុងយឿង( វៀតណាមកណ្ដាល ), នៅទួលលេគុនតាំង ( សុមាត្រា ) នៅដេមែរ្យូន ( ជ្វា ), នៅស៊ីកេងដេង ( កោះសេឡេប ) ។ ឯព្រះពុទ្ធរូបនៅនគររាជសីមា នៅនគរបឋម ( សៀម ) ជាការរចនាភ្នំដា នៅអង្គរបុរីដែរ ។ នៅបុរាណដ្ឋាន អូ- កែវ សម័យនគរភ្នំ

---

"១" B.P.Groslier,Etudes Asiatiques,BEFEO.I,P. 304 .

"២" L.Malleret,Pour comprendre la sculpture Bouddhique et Brahmanique en Indochine PL . III

"៣" P.Dupont, statuaires préankoriennes, P. 190 .

www.budinst.gov.kh www.elibraryofcambodia.org

លោក ល.ម៉ាល្លីរេតិ៍ (L.Malleret) បានរកឃើញព្រះពុទ្ធរូបបុរាណថ្មី ពីសំរិទ្ធច្រើនអង្គ ដែលមានការរចនាតាមបែប គុប្តៈ និង អមរាវតី ។

សេចក្តីរៀបរាប់មកខាងលើនេះ បង្ហាញអោយឃើញថា ពុទ្ធសាសនាថេរវាទ មានការរីកចំរើនរុងរឿងក្នុងសម័យនគរភ្នំ ប៉ុន្តែតមក មានស្តេចមួយអង្គមិនសព្វព្រះទ័យ ទ្រង់បំផ្លាញចោលអស់ទៅ "១" ។

៣_ សម័យចេនឡា :

- ពីពុទ្ធសតវត្សទី១១ ដល់ទី ១៤ ( ព.ស ១០៩៣_ ១៣៤៥ )
- គ្រិស្តសតវត្សទី ៦ ដល់ទី ៩ ( គ.ស ៥៥០_ ៨០២ )

ពង្សាវតារចិន ( រាជវង្ស តាំង ) នៅដើមពុទ្ធសតវត្សទី១១ (គ្រិស្តសតវត្សទី ៦ ) និយាយថា នៅប្រទេសហ្វូណន មានការភ័ន្តប្រែ នៅក្នុងប្រទេស ។ ប្រទេសចេនឡា លើកទ័ពមកវាយក្រុងទូមូ (To-Mou) = វ្យាធបុរៈ (បាភ្នំ) ហើយស្តេច វ្យាធបុរៈ ចេញទៅគង់នៅក្រុងខាងត្បូងឈ្មោះ ណា_ហ្វូ_ណា ( Na - Fou - Na ) គឺនរវរនគរ ( អង្គបុរី ) ។ ពង្សាវតារចិន (រាជវង្ស ស៊ួយ )និយាយថា មានក្សត្រប្រទេសចេនឡា នាម ចេ_ទូ_សេ_នា ( ចិត្រសេនា ) គឺព្រះបាទភវវរ្ម័នទី ១ មកដណ្តើមយកក្រុងភ្នំបាន ។ សម័យនេះ អ្នកប្រាជ្ញប្រវត្តិសាស្ត្រសន្មតឈ្មោះថា " សម័យចេនឡា " ។ មានស្តេចសោយរាជ្យតសន្តតិវង្សមក គឺព្រះបាទភវវរ្ម័នទី ២ ចិត្រសេនា (ពាក់កណ្តាលគ្រិស្តសតវត្សទី ៦) មហេន្ទ្រវរ្ម័ន (ចុងគ្រិស្តសតវត្សទី ៦ ) ឦសានវរ្ម័ន (គ.ស ៦១៦_៦២៦) ភវវរ្ម័នទី ២ ( គ.ស ៦៣៩ ) ជ័យវរ្ម័នទី ១ (គ.ស ៦៥៧_៦៨១) ។ ពុទ្ធសាសនាថេរវាទចំរើនរុងរឿងនៅឡើយ តែសម័យនេះ មានការប្រែប្រួលគួរអោយកត់សំគាល់ គឺមានពុទ្ធសាសនាលទ្ធិមហា

www.budinst.gov.kh www.elibraryofcambodia.org

យាន ចូលមកក្នុងប្រទេសកម្ពុជា ឃើញមុនដំបូងបង្អស់ នៅដើមពុទ្ធសតវត្សទី ១២ ។

ក្នុងរជ្ជកាលព្រះបាទ ឦសានវរ្ម័នទី ១ ( គ.ស ៦១៦_ ៦២៦ ) មាន សិលាចារឹកមួយនៅសំបូណ៌ព្រៃគុក ( ឦសានបុរៈ ) "១" ខេត្តកំពង់ធំ ក្នុង គ.ស ៦២៦ បញ្ជាក់ថាមានពុទ្ធសាសនា ។ មានការគោរពនាគរាជ មុចលិន្ទ ដែលបាំងព្រះពុទ្ធរូប ។ សិលាចារឹកនេះនិយាយពីព្រាហ្មណ៍ឈ្មោះ បសុបតិ ងារជាវិទ្យាវិសេសៈ ជាអ្នកប្រាជ្ញមានការចេះដឹងខ្ពង់ខ្ពស់ ចេះអធ្វ័ន គឺផ្លូវវិទ្យា ខាងវេយ្យាករណ៍ ខាងវៃសេសិកៈ ខាងន្យាយៈ ខាងសមីតក្រ សាំខ្យា និង ពុទ្ធសាសនា ។ ក្នុងសិលាចារឹក នៅភ្នំបាទាយាំ ក៏ឃើញមានព្រាហ្មណ៍ឈ្មោះ បសុបតិ នេះដែរ ។ លោក សឺដែស បានសរសេរថា សិលាចារឹកនេះជាគ្រឿងសំគាល់អោយដឹងថាមាន សិលាចារឹកពុទ្ធសាសនា ជាដំបូងក្នុងសម័យចេនឡា ។

ក្នុងរជ្ជកាលព្រះបាទភវវរ្ម័នទី ២ (គ.ស ៦៣៩) មានសិលាចារឹក មួយនៅភូមិខាវរាំង ជិតអរញ្ញប្រទេស ( សៀម ) ដែលថ្លែងពីឧបាសកម្នាក់ ងារជាសីនាហូ បានសាងព្រះវិហារមួយឧទ្ទិសថ្វាយពុទ្ធសាសនា ព្រមទាំង ថ្វាយទ្រព្យសម្រាប់វិហារ និង ទាសាចាស់ក្មេងចំនួន ៣៦នាក់ រាប់ទាំងអ្នក រក្សាចំការដូង ស្លា ច្រើនរយផង ។

ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ១ ( គ.ស ៦៥៧_ ៦៨១ )មាន សិលាចារឹកពីរ "២" មួយនៅវត្តព្រៃវៀវ ( គ.ស ៦៦៤ ) ស្រុកកំពង់ត្រ-បែក ខេត្តព្រៃវែង ( ពីដើមជាខេត្តបាភ្នំ ) ដែលទុកថា មានភិក្ខុពីរអង្គ ជាបងប្អូនបង្កើតជាតិជាកម្រេត ចេញទ្រង់បព្វជ្ជា ហើយគង់នៅវត្តព្រៃ-

---

"១" L. Finot, BEFEO . XXXIII , P. 44 et suiv

"២" A.Barth, inscription du Cambodge , P. 60 et suiv

វៀរនេះ ។

វត្តព្រៃវៀរ ជាវត្តមួយបរមបុរាណ តាំងពីកាលនោះរហូតមក ដល់សព្វថ្ងៃនេះ ។ អ្នកស្រុកជិតខាងវត្ត ចាំរឿងបុរាណត ពុគ្នាមក និយាយតពាក្យថាវត្តនេះ ស្ដេចសម័យដើមបានថ្វាយចំពោះព្រះសង្ឃ ហើយ ប្រគល់អោយភិក្ខុពីរអង្គ ជាកន្រ្តត្រូវជាបងប្អូនបង្កើតថែរក្សា ហើយហាម ប្រាមមិនអោយជនណាមួយទៅបៀតបៀនវត្តនេះទេ ។ អ្នកស្រុកហាមប្រាម កូនចៅត ពុគ្នាមក អោយវៀរមិនអោយទៅកាប់ឈើព្រៃក្នុងវត្តនេះ នោះ ហើយខ្លាចតព្វ គ្នារហូតមក បានជាវត្តនេះមានឈ្មោះថា " វត្ត ព្រៃវៀរ " ។

សិលាចារឹកមួយទៀត នៅវត្តប្រាសាទ ស្រុកកំពង់ត្របែក ខេត្ត ព្រៃវែង ( ពីដើមជាខេត្តបាភ្នំ ) និយាយពីការថ្វាយទាសៈចំពោះពោធិ. សត្វ ៣ អង្គ គឺ ឈ្មួៈ ១ មៃត្រេយៈ ១ និង អវលោកិតេស្វរៈ ១ ។ លោក អាយម៉ូនិយេ ថា សិលាចារឹកនេះ នៅក្នុងគ្រិស្ដសតវត្សទី ៦ ឬ ទី ៧ ។ មានសិលាចារឹកមួយទៀត នៅសៀមរាប ( គ.ស ៧៩១ ) និយាយពីការកសាងរូបពោធិសត្វ អវលោកិតេស្វរៈ ទុកដើម្បីគោរពបូជា បូជនីយដ្ឋាននេះ សព្វថ្ងៃហៅថា ប្រាសាទ " តាកៀម " ។

សេចក្ដីនេះ ឆ្លើយស្របគ្នានឹងឯកសារចិនដែរ ។ ប្រវត្តិសាស្ត្រ យើងក្នុងសម័យចេនឡា ( គ្រិស្ដសតវត្សទី ៧ ) ក្នុងរជ្ជកាលព្រះបាទ ឦសាន វរ្ម័ន មាននៅក្នុងប្រវត្តិសាស្ត្រចិន ( រាជវង្ស ស៊ួយ ) ដែលនៅក្នុងនោះ លោក ម៉ា - ទួន លិន "២" បានសរសេរកាលពីគ្រិស្ដសតវត្សទី ១៣ ថា :

" ស្ដេចប្រថាប់ នៅក្នុងរាជធានី ក្រុង ឦ -ចូ- ណា ឦសាន បុរៈ ។ ក្រុងនេះមានគ្រួសារជាង ២០ គ្រួសារ ។ នៅកណ្ដាល

---

១ G.Cocdès,Hitoire ancienne des Etats hindouisés d'Extrême - Orient , P. 90 et suiv .

ក្រុងមានប្រាសាទមួយដែលទ្រង់ប្រើប្រាស់ទទួលរាជបរិពារ ។ ក្នុងរាជាណាចក្រទាំងមូល មានទីក្រុង ៣០ ។ ក្រុងនីមួយៗ មានទីលំនៅនៃគ្រួសារច្រើនណាស់ ហើយមានចៅហ្វាយខេត្តម្នាក់ត្រួតត្រា ។ ស្ដេចចេញទៅកាន់ទីសាលប្រជុំ ជាឧទ្យានិក ៣ ថ្ងៃម្ដងទៀងទៅ ទ្រង់ប្រថាប់លើព្រះទែនធ្វើពីខ្លឹមចន្ទន៍ក្រឹស្នា ៥ ប្រភេទ ដែលប្រដាប់ដោយរតនវត្ថុ ៧ ប្រការ លើព្រះទែនមានស្វេតឆត្រ ផងធ្វើពីឈើមានផ្កា មុខព្រះទែនប្រកបភ្លុករាយផ្កាមាស ខាងក្រោយមានវង់រស្មីមាស ...។ នៅជិតក្រុងមានភ្នំមួយ ឈ្មោះ លិង-គា-ប៉ុ-ប៉ូ គឺលិង្គបព៌ត ។ នៅលើកំពូលភ្នំនេះ មានទេវាល័យមួយដែលដាក់ខ្លួងសំលាប់មនុស្សធ្វើយញ្ញពិធី មានទាហានមួយពាន់នាក់នៅចាំរក្សា ។ នៅចេនឡា មានប្រជាជនច្រើនកាន់ពុទ្ធសាសនា ។ អ្នកស្រុកធ្វើស្រែ ចំការ ...' ។

ក្នុងសម័យចេនឡា យើងឃើញថា ពុទ្ធសាសនាលទ្ធិមហាយានរុងរឿង តែមិនសូវមានរូបអវលោកិតេស្វរៈទេ មានមួយនៅខេត្តក្រមួនស មួយទៀតនៅប្រាសាទតាមកៀប ( សៀមរាប ) ។ ឯព្រះពុទ្ធសាសនា ថេរវាទក៏មិនមែនសាបសូន្យដែរ ។

៤- សម័យមហានគរ :

- ពុទ្ធសតវត្សទី ១៤ ទៅទី ២០ ( ព.ស ១៣៤៥-១៩៧៥ )
- គ្រិស្តសតវត្សទី ៩ ទៅទី ១៥ ( គ.ស ៨០២-១៤៣២ )

ព្រះបាទជ័យវរ្ម័នទី ២ ទ្រង់ឡើងសោយរាជ្យក្នុងព.ស ១៣៤៥ ( គ.ស ៨០២ ) ទ្រង់រៀបពិធីតាំងរាជធានីនៅលើមហេន្ទ្របព៌ត គឺភ្នំគូលែន ។ កាលនោះ ទ្រង់បាននិមន្តព្រាហ្មណ៍ម្នាក់ឈ្មោះ ហិរណ្យទាមៈ អោយមកជួយរៀបហោមពិធី ប្រកាសឯករាជ្យជាចក្រពត្រាធិរាជ

www.budinst.gov.kh www.elibraryofcambodia.org

ហើយលើកកិត្តិយសព្រះអង្គជាគ្រូអង្គ "ទេវរាជ គឺ ព្រះហរិហរៈ" ដំបូងបង្អស់ក្នុងប្រវត្តិសាស្ត្រកម្ពុជាយើង ។ ព្រះបាទជ័យវរ្ម័នទី ២ ជាស្តេចមួយអង្គប្រសើរវិក្រមលែង ទ្រង់បានបង្រួបបង្រួមប្រទេសដែលបាក់បែកគ្នា នោះអោយមកជាប្រទេសបានឯកភាពឡើងវិញ ។ ស្តេចអង្គនេះ កាន់សាសនាព្រាហ្មណ៍ គោរពព្រះ ហរិហរៈ ទ្រង់មិនបានកាន់ពុទ្ធសាសនាទេ តែពុទ្ធសាសនា ទាំងពីរនិកាយ ក៏នៅជាមួយគ្នាដូចដើម ។

តាំងពីពុទ្ធសតវត្សទី ១៤ ( គ្រិស្តសតវត្សទី ១០ ) ទៅរហូតមក យើងសង្កេតឃើញថា មានសភាពប្លែកពីអតីតកាល "១" គឺស្តេចនិងមន្ត្រីកាន់សាសនា មិនដូចគ្នាទេ បើស្តេចកាន់សាសនាព្រាហ្មណ៍ មន្ត្រីកាន់ពុទ្ធសាសនា បើស្តេចកាន់ពុទ្ធសាសនា មន្ត្រីកាន់សាសនាព្រាហ្មណ៍វិញ ។

ព្រះបាទឥន្ទ្រវរ្ម័នទី ១ ទ្រង់ឡើងសោយរាជ្យក្នុង គ.ស ៨៧៧ ទ្រង់តាំងរាជធានី នៅរលួស ស្រុកស្ទូងព្រនិគមសព្វថ្ងៃនេះ ប្រាសាទបាគង ជាហរិហរាល័យ [illegible] ព្រះ ហរិហរៈ ។ ស្តេចអង្គនេះកាន់សាសនាព្រាហ្មណ៍ គោរពព្រះហរិហរៈ តែទ្រង់ប្រោសប្រាណពុទ្ធសាសនាដែរ ។ សិលាចារឹកប្រាសាទព្រះគោ កាលពី គ.ស ៨៧៩ បានប្រើពាក្យថា "កម្ពុជ:" ឬ "កម្ពុជទេស" មុនដំបូងក្នុងប្រវត្តិសាស្ត្រយើង ។

ព្រះបាទយសោវរ្ម័នទី ១ ជារាជបុត្របានឡើងសោយរាជ្យពី គ.ស ៨៨៩ ហើយទ្រង់លើករាជធានីទៅនៅទីក្រុង ឈ្មោះ "យសោធរបុរៈ" គឺអង្គរសព្វថ្ងៃនេះ ។ ស្តេចអង្គនេះ ជាពុទ្ធសាសនិក ទ្រង់បានទទួលស្គាល់ពុទ្ធសាសនាមហាយានជាផ្លូវការមុនដំបូងបង្អស់ក្នុង

---

"១". G. Coedès, Histoire ancienne des Etats hindouisés d'Extrême - Orient, p. 153.

ប្រវត្តិសាស្ត្រប្រទេសយើង ដែលទ្រង់ទ្រួសប្រណីតសាសនាព្រាហ្មណ៍ ដូចពុទ្ធ-
សាសនាដែរ ។ កាលនោះពុទ្ធសាសនា និង សាសនាព្រាហ្មណ៍ មិនមាន
ការបៀតបៀនគ្នាទេ ។

ព្រះបាទរាជេន្ទ្រវរ្ម័ន ( ឥន្ទ្រវរ្ម័នទី ២ ) ទ្រង់ឡើងសោយ
រាជ្យក្នុង គ.ស ៩៤៤ ទ្រង់កាន់សាសនាព្រាហ្មណ៍ គោរពព្រះឥសូរ តែ
ទ្រង់ទ្រួសប្រណីតពុទ្ធសាសនាដែរ ។ ក្នុងរាជ្យនេះ សាសនាព្រាហ្មណ៍
លទ្ធិព្រះឥសូរ និង ពុទ្ធសាសនា រលាយចូលគ្នាជាប់រហូតមក ។

ព្រះបាទជ័យវរ្ម័នទី ៥ ជារាជបុត្រព្រះបាទរាជេន្ទ្រវរ្ម័ន ឡើង
សោយរាជ្យក្នុង គ.ស ៩៦៨ ។ ស្ដេចអង្គនេះកាន់សាសនាព្រាហ្មណ៍ដែរ
តែរាជត្រកូល និង មន្ត្រីជាន់ខ្ពស់កាន់ពុទ្ធសាសនា ។ ក្នុងសិលាចារឹកនៅ
វត្តស្រីសន្ធរ ពួកអ្នកប្រាជ្ញយល់ថា " មានការរលាយសាសនាព្រាហ្មណ៍ និង
ពុទ្ធសាសនា ចូលគ្នា មុនដំបូងបង្អស់ នៅក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជា " ។

ព្រះបាទសូរ្យវរ្ម័នទី ១ បានឡើងសោយរាជ្យក្នុង គ.ស ១០០២ ។
ស្ដេចអង្គនេះ ជាបឋមក្សត្រពុទ្ធសាសនិកដែលបានទទួលស្គាល់ពុទ្ធសាសនា ជា
ផ្លូវការ ក្នុងសម័យមហានគរ ។ ពុទ្ធសាសនាមហាយាន បានរីករាយឥទ្ធិពល
ចូលមក ប្រទេសយើងយ៉ាងខ្លាំងក្នុងរាជ្យព្រះអង្គ គម្ពីរដីកាក្ដី ក្បួនរាជាចារ្យ
ក្ដី សុទ្ធសឹងតែចេញមកពី ក្រាំព្រលិង្គៈ ( តាម្ពលិង្គៈ ) នៅជ្រោយ
ម៉ាឡាយូ ដែលជាមជ្ឈមណ្ឌលផ្សាយពុទ្ធសាសនា ។ ក្នុងរជ្ជកាលព្រះអង្គ
រាជាណាចក្រកម្ពុជា ធំទូលាយណាស់ ព្រោះបានរួមទាំងលពបុរី
( លវបុរី ) ជាអាណាចក្រមន ការ័វទ្វារាវតី ជាដែនដីដែល មនមក
ពី ថាតុង ( សុធម្មបុរៈ ) និង ប៉េគូ ព្រមទាំង មននៅទន្លេ មេណាម
និង ទន្លេ ឥរាវឌី ( ឥរាវតី ? ) ។ ស្ដេចអង្គនេះ ទ្រង់ជាពុទ្ធសាស-
និក លទ្ធិមហាយាន តែបានទ្រួសប្រណីតពុទ្ធសាសនាថេរវាទ និងសាសនា

www.budinst.gov.kh www.elibraryofcambodia.org

ព្រាហ្មណ៍ផងដែរ ។ អ្នកប្រាជ្ញខាងសិល្បៈសាស្ត្រ បានរកឃើញថា មានការកើតព្រះពុទ្ធរូបប្រក់នាគជាដំបូងក្នុងរាជ្យព្រះអង្គ ដែលមិនធ្លាប់មានមកពីអតីតកាល ។ ពិតមែនតែជាក្សត្រ ពុទ្ធសាសនិក តែទ្រង់នៅគោរព "ទេវរាជ" តាមប្រពៃណីរាជសម្បត្តិដូចដើម ។ លុះទ្រង់ទិវង្គតទៅ គេថ្វាយព្រះបរមនាមព្រះអង្គថា "ព្រះនិវ៌ាណបទ" ។

ព្រះសូរ្យវរ្ម័នទី ២ ឡើងសោយរាជ្យក្នុង គ.ស ១១១៣ ។ ទ្រង់កាន់សាសនាព្រាហ្មណ៍ គោរពព្រះវិស្ណុ ហើយប្រហែលជាទ្រង់ទិវង្គតក្នុង គ.ស ១១៥០ ។ តមក ព្រះបាទធរណិន្ទ្រវរ្ម័នទី ២ ឡើងសោយរាជ្យ ព្រះនាងស្រីជយរាជចូឌាមណី ជាអគ្គមហេសី មានរាជបុត្រមួយអង្គ ព្រះគរ ជាលក្ខណាបវរគ្រប់ប្រការ ជាបុត្ររាជកុមារ ទៅអនាគត គឺ ព្រះបាទជ័យវរ្ម័នទី ៧ ។ ព្រះបាទធរណិន្ទ្រវរ្ម័ន ទ្រង់កាន់ពុទ្ធសាសនាមុនបង្អស់ ។

ព្រះបាទជ័យវរ្ម័នទី ៧ ឡើងសោយរាជ្យក្នុង គ.ស ១១៨១ ។ ព្រះអង្គជាព្រះរាជាមានកិត្តិនាមល្បីល្បាញបំផុត ក្នុងប្រវត្តិសាស្ត្រកម្ពុជា ទ្រង់ជាពុទ្ធសាសនិក ដ៏ខ្ជាប់ គោរពពោធិសត្វ លោកេស្វរៈ ។ ប្រពៃណីគោរព "ទេវរាជ" "១" ពីបុរាណកាល គឺ តាំងពី គ.ស ៨០២ មក ព្រះអង្គប្រែឲ្យជាគោរព "ពុទ្ធរាជ" វិញ ។ ពិតមែនតែទ្រង់កាន់ពុទ្ធសាសនាមហាយាន តែទ្រង់ក៏ប្រណីសាសនាព្រាហ្មណ៍ដែរ ។ សិលាចារឹកនៅអង្គរធំ "២" ថែងថា "នៅប្រទេសកម្ពុជា មានអ្នកប្រាជ្ញចេះដឹងត្រៃវេទច្រើនណាស់" ។ មានបដិមា ២ ដែលគេជឿថាជាបដិមាព្រះបាទជ័យវរ្ម័នទី ៧ គឺព្រះអង្គមានកាយធំស័ក្តិសម ព្រះ...

---

"១" G. Coedès, Inscription de Pra Khan BEFEO, XLI, P.285

"២" L. Finot, Les inscriptions d'Angkor, BEFEO, XXV, P.403.

បួន ។ បដិមាមួយនៅប្រាសាទអង្គរធំ "១" មួយទៀតនៅប្រាសាទ ពិ-មាយ "២" ( ប្រទេសសៀម ) ហើយគេយកដំកល់ទុកនៅសារមន្ទីរក្រុងបាងកក ។

ក្នុងរជ្ជកាលព្រះអង្គ ប្រាង្គប្រាសាទរាជដ្ឋាន មានកំពូលខ្ពស់ស្រដួច ត្រដឹង ស្កឹមស្កៃ សុទ្ធសឹងលោកេស្វរៈ សម្មុខ ព្រះនេត្របិទពាក់កណ្ដាល សំឡឹងចុះមកក្រោម ហើយព្រះភក្ត្រញញឹមស្រស់ប្រិមប្រិយ ហៅថា "ញញឹមបែបសិល្បៈអង្គរ" គង់មើលទៅឃើញហាក់បីដូចជា តួអង្គព្រះបាទជ័យវរ្ម័នទី ៧ ដែលជាតួអង្គព្រះពោធិសត្វ អវលោកិតេស្វរៈ យាងចុះពីស្ថានសុខាវតី មកថ្នាក់ថ្នមថែរក្សា ប្រជាជនខ្មែរ អោយបានសេចក្ដីសុខក្សេមក្សាន្ត ប្រាសចាកទុក្ខភ័យ ។ ទ្រង់បានកសាងប្រាសាទបន្ទាយក្ដី, តាព្រហ្ម, ព្រះខាន់, [illegible], មន្ទីរពេទ្យ, សាលាសំរាកតាមផ្លូវធំ ដែលទ្រង់កសាងពីមហានគរ ទៅពិមាយ (សៀម) និងទៅប្រទេស ចាម្ប៉ា ។ ក្រៅពីនៅរាជធានី (មហានគរ) ទ្រង់បានកសាងប្រាសាទវត្តនគរ (កំពង់ចាម), តាព្រហ្ម ទន្លេបាទី (តាកែវ), ប្រាសាទមួយនៅបន្ទាយឆ្មា ឧទ្ទិសព្រះស្រីន្ទ្រកុមារ ជាបុត្រ និង នៅកន្លែងដទៃទៀតច្រើនអនេក ដើម្បីសំរេចតាមព្រះរាជបំណងថា "ធ្វើប្រទេសកម្ពុជា អោយក្លាយទៅជាឋានសួគ៌" ។

ទ្រង់សាងប្រាសាទ តាព្រហ្ម ហើយដាក់ឈ្មោះថា "ព្រះរាជ-វិហារ" ( គ.ស. ១១៨៦ ) ឧទ្ទិសថ្វាយព្រះមាតា ដើម្បីតំកល់បដិមាព្រះនាងជ័យរាជចូឌាមណី ជារាជមាតា ។ សិលាចារឹកនៅប្រាសាទតាព្រហ្ម "៣"

---

"១" G.Coedès, Pour mieux comprendre Angkor .

"២" G.Coedès, les collections archéologiques au Musée National de Bangkok , XII , 18 – 19 .

"៣" G.Coedès, la stèle de Ta Prom(BEFEO,VI,P.44)

ជាស្នាព្រះហស្តរាជបុត្រព្រះអង្គ ឈ្មោះសូរ្យកុមារ ទ្រង់តែងឡើង រៀបរាប់ពីការកសាង និង ការទំនុកបំរុងវត្តនេះ ឲ្យដើមនមស្ការ សរសើរ ថ្វាយព្រះបាទជ័យវរ្ម័នទី ៧ , បញ្ចុះវត្ថុ គ្រឿងឧបភោគបរិភោគ និងតួស៍-រាប់ពុទ្ធបូជា ។ សិលាចារឹកនោះមានសេចក្តីបកប្រែដូចតទៅ :-

( សេចក្តីដកស្រង់ )

ៈបណ្ណា ៤ ព្រះខេត្តក្រឹយ

" ព្រះពុទ្ធដ៏មានបុណ្យញាណ បានកាយចែកជា៣ ចំណែក. គឺធម៌កាយ ១ សម្ភោគកាយ ១ និម្មានកាយ ១ ដែលជាផលកើតចេញមកពីសម្ភារៈ គឺ បុណ្យ ខ្ញុំសូមនមស្ការចំពោះអង្គព្រះពុទ្ធនោះ ដែលជាចំណែកនៃខាងកាយព្រះ និងស្រី និង បុត្រនៃព្រះ និងស្រី ហើយកើតឡើងជាសរណៈ នៃសត្វលោក " ។

" ខ្ញុំសូមក្រាបបង្គំចំពោះព្រះធម៌ដ៏ខ្ពង់ខ្ពស់ ជាមាគ៌ា នៃពោធិញ្ញាណ ដ៏ប្រសើរ ជាគ្រឿងនាំចេញអំពីសង្សារវដ្តដ៏ពិត ដែលជាធម៌ គឺពួកអមរ ក្នុងត្រៃភពគួរគោរពបូជា ទុកជាព្រះខាន់សំរាប់កាប់បំផ្លាញនូវគុម្ពព្រៃ ពោលគឺ សឹកសត្រូវ ខាងក្នុង ៦ ប្រការ ។

" ដោយអានុភាពព្រះសង្ឃដែលបានប្រកបនៃប្រយោជន៍រួមគ្នា សូមឲ្យអង្គលោករួចស្រឡះហើយជាយកឈ្នះ អំពីសឹកសត្រូវ និងវិមុត្តិញាណ ប៉ុន្តែលោកនៅជាប់ទាក់ទងនឹងប្រយោជន៍ នៃជនដទៃ ដែលអង្គលោកបានប្រ-តិបត្តិ គតិ មកហើយ អង្គលោកស្វាធ្យាយដល់អង្គលោកផង បង្រៀននូវធម៌សាសនាដល់ជនដទៃទាំងឡាយផង សូមការពារនូវលោកអ្នកទាំងឡាយ ក្រអួតក្អេង កុំឲ្យឃ្លាតឃ្លាឡើយហោង " ។

ព្រះសូរ្យកុមារ ជារាជបុត្រសរសើរបារមីចំពោះអង្គព្រះបាទជ័យវរ្ម័នទី ៧ ជាអនេកប្បការតទៅទៀត ត្រង់គាថាទី ៣៥ និងទី៣៦

www.budinst.gov.kh www.elibraryofcambodia.org

ដែលនិយាយពីការកសាងព្រះរាជវិហារ ( ប្រាសាទតាព្រហ្ម ) សំរាប់ដំ-
កល់បដិមា ព្រះនាង ស្រីជយរាជ ចូឌាមណី ទ្រង់មានបន្ទូលថា :-

( ឧត្សាទិកា .... )

" បុរីឈ្មោះរាជវិហារ ប្រាសាទតាព្រហ្ម នេះមានអង្គប៉ិតក្រាង ហើយដោយសុវណ្ណ ក៏ប្រុះស្លះប្រទាក់ដោយពេជ្រ ( ទ្រង់ព្រះឫទ្ធិដ៏យរដ៏ថ្មីទំ-ពាំ ) បានកសាងនៅលើដែនដី ដែលព្រះអង្គបង្រាំងបេកមកបានដោយព្រះហស្តព្រះអង្គ ដើម្បីដំកល់ទុករូប មុនិន្ទ្រ មាតា ។

" ទ្រង់ដំកល់ទុកនូវបដិមា នៃព្រះជននីព្រះអង្គ ព្រះនាមស្រីជយរាជ ចូឌាមណី ដែលមានព្រះកាយក្លែងផ្លែកផ្កាដែកនិបណ៌ ទុកជាអង្គបដិមា នៃព្រះជិនមាតាក្នុងឆ្នាំ ១១០៨ ម.ក " ( +៧៨ = ១១៨៦ គ.ស ) ។

តទៅ សិលាចារឹកនេះ រៀបរាប់អំពីពុំបូវត្ថុអាហារភោជន និង គ្រឿងប្រើប្រាស់សំរាប់ទំនុកបំរុងវត្ត " ព្រះរាជវិហារ " នេះទៀត គឺ : អង្ករ , ល្ង , សណ្តែកដី , សណ្តែកវាំងមាស , ទឹកដោះខាប់ , ទឹកឃ្មុំ , ទឹកភេសជ្ជៈផ្អែម , ប្រេងល្ង និង គ្រឿងប្រដាប់ដទៃទៀត ... ។

ព្រះរាជទ្រព្យ និង ទេយ្យទានពីអ្នកបានទ្រព្យនៅស្រុក៣.១៤០ ស្រុក សំរាប់ឧបត្ថម្ភ គឺ :

បុរស ៤០០ នាក់ , អធិការ ( មហាថេរ ) ១៨អង្គ , អធិការរង (អនុថេរ ) ២.៧៤០អង្គ , បរិវារិកៈ (អ្នកបំរើ ) ២.២៣២នាក់ , រួមទាំងបុរិចារិកា ៦១៥នាក់ ជានាងពិគ្គី ( ស្រីល្ខោន ) ផង , ពួករួមទាំងអស់ ១២.៦៤០នាក់ រាប់ទាំងអ្នកដែលដេកនៅក្នុងទីនោះផង , ស្ត្រីបុរស ៦៦.៦២៥ នាក់ សំរាប់បំរើទេវរូប , ពួករួម ៧៩.២៦៥នាក់ ព្រមទាំងជាតិ បូមាម និង ចាមផង ( ភូមា និង ចាម ) .... ។ ( មានមាស ,

www.budinst.gov.kh www.elibraryofcambodia.org

ប្រាក់ , ពេជ្រ , គជខ្យង : ត្បូង , ស្ពាន់ , សំណរ , ដែងសំណរ , ខ្នុះមាស , ចានស្ពាន់ , សំពត់ចិន , កំរាលស្បូរ ...) ។ ធ្វើបុណ្យខែចេត្រពីថ្ងៃទី ៨ ទៅ ថ្ងៃពេញបូណ៌មី តាមប្រពៃណីព្រះជិនស្រី ។

គេរៀបរាប់ពីការបុណ្យកិរិយាវត្ត ដែលទ្រង់បំពេញនិងសំដែងអស្ចារ្យ យ៉ាងនេះហើយ ទ្រង់ឱ្យសរសេរព្រះរាជកុសលថ្វាយព្រះវររាជមាតា ដោយគាថាដូច្នេះ (កុរីជ្ជីមាធិ... ) :-

" ដោយផលបុណ្យ ដែលទ្រង់ ( ព្រះបាទជ័យវរ្ម័នទី ៧ ) បានបំពេញ ដោយប្រទេះថ្វាយព្រះវររាជមាតាយ៉ាងនេះហើយ ព្រះរាជាតាំងប្រណិធានថា " ដោយអំណាចបុណ្យរាសីនេះ សូមព្រះវររាជមាតាដែលឆ្លងផុតបាត មហាសាគរ គឺភពហើយ ឲ្យសំរេចនូវការជាព្រះជិនស្រី កុំឃ្លាតឡើយ " ។

ក្រោយពីបានកសាងព្រះរាជវិហារមកបាន ៥ ឆ្នាំ ក្នុង គ.ស ១១៩១ ទ្រង់បានកសាងប្រាសាទមួយទៀត ឈ្មោះប្រាសាទ " ជ័យស្រី " ឧទ្ទិសថ្វាយព្រះពុទ្ធសាសនា សព្វថ្ងៃហៅប្រាសាទព្រះខ័ន ដើម្បីដំកល់បដិមា ព្រះបាទធរណីន្ទ្រវរ្ម័ន ជារាជបិតា ទុកជាអង្គទេពាធិទេព លោកេស្វរៈ ហើយថ្វាយនាមថា " ជយវរ្មេស្វរៈ " ។ នៅទិសខាងកើតក្នុងវង់ (បរិវេណ) ប្រាសាទព្រះខ័ន ទ្រង់បានកសាងប្រាសាទមួយមានឈ្មោះថា " រាជ្យស្រី " សព្វថ្ងៃហៅប្រាសាទ " នាគព័ន្ធ " នៅចំកណ្តាលស្រះ ជាប្រាសាទតូចមួយ មាននាគព័ន្ធពីក្រោម ហើយមានស្រះ ៤ នៅគ្រប់ទិស ។ ស្រះនីមួយៗ មានទេវរូបរាប់បង្ហូរទឹកលាងបាបចេញពីស្រះកណ្តាល ដែលជាតួប្រាសាទ នាគព័ន្ធ ។ ប្រាសាទ " រាជ្យស្រី " នេះ ជាកំពង់បុណ្យសំរាប់លាងបាប ទាញយកលំអពីស្រះទាំង ៤ ទិស សាងតំណាងអនោតត្តស្រះ

www.budinst.gov.kh www.elibraryofcambodia.org

ទៅភ្នំព្រះសុមេរុ ( ភ្នំហិមាល័យ ) ដែលនិយាយថា មានកំពង់ ៤ ហូរចុះទៅកាត់ទិសទាំង ៤ តាមប្រពៃណីប្រទេសឥណ្ឌា ហើយបានសាងបដិមារូបព្រះអង្គទុកជាអង្គព្រះពុទ្ធ ត្រូវពេជ្រ ដំកល់ទុកក្នុងប្រាសាទនេះផង បើ-ទាប់ជួយសង្គ្រោះសត្វលោកដែលមានជំងឺ ។ រូបនេះមួយដែលមានចុងក្រោមមនុស្ស គោង ក៏ជាបដិមារូបព្រះអង្គដែរ មានន័យថា " ព្រះអង្គដឹកជញ្ជូនសត្វលោក ពីមហាសាគរ គឺវាលវដ្តសង្សារទីក្រភព ទៅកាន់ទីក្សេមក្សាន្ត គឺ ព្រះនិព្វាន " ។ រឿងទាំងនេះ ដូចសិលាចារឹកនៅប្រាសាទព្រះខាន់ដែលចារឹកទុកថា :- "២"

( សុទ្ធចិទ្វិរចិតាយៅ ... )

" ត្រង់ ( ព្រះបូទដីការទ្វីនទី ៣ ) បានសាងស្រះរាជ្យស្រី ( នាគ-ព័ន្ធ ) ទុកដូចកញ្ចក់ ភ្លឺដោយផែនថ្ម ទ្វារ និង កប្រងផ្កាមាសទុកក្នុងប្រាសាទជ័យស្រី ( ព្រះខាន់ ) ប្រាកដ ដូចក្នុងព្រះកេសាដែលស្បងដោយសិល្បៈយ៉ាងប្រពៃ នៃព្រះអគ្គមហេសី ដែលតាក់តែងវិចិត្រ មុខគួរអោយរីករាយ ។

" ព្រះ រាជ្យស្រីនេះ មានទឹកថ្លាឈ្វង់ឈ្វៃ ស្ពះស្របមោលនៃពន្លឺប្រាសាទមាស និង ពណ៌ផ្កាឈូកក្រហម បោលពន្លឺភ្លឺព្រាលផ្ទិនឆ្លៀតប្រាកដ ដូចជា ស្រះយោមដែលស្រោះបាទ ភាគទី: ( ចក្រ ចាមញុំ ) ធ្វើអោយហូរ ហ្លាប ( ក្នុងចំប៉ាំង ) ។

" នៅកណ្តាល ស្រះរាជ្យស្រីនេះ មានកំពង់បុណ្យសំរាប់លាងបាបមួយ ទាញយកលំអស្រស់មកពីស្រះ ( គ្រប់ទិសទាំង ៤ ) ជាកំពង់បុណ្យសំរាប់លាងបាបនៃជនណាដែលបានចូលទៅ ជាសំពៅឆ្លងកាត់ដឹកជញ្ជូនសត្វ

---

"១" G.Coedès, la stèle de Pra Khan ( BEFEO, XLI, P.282) -

លោក កាត់ឆ្លងមហាសាគរ អោយចេញចាកទីក្រុងភព ( ទៅកាន់ អមតមហានិព្វាន ) [១] ។

ទ្រង់បានសាងប្រាសាទក្រៅពីកន្លែងទៀត លំដាប់ពីកល់ពុទ្ធរូបនិមា ឆាយ " ព្រះជ័យពុទ្ធមហានាថ " [៦] ដើម្បីដោះស្រាយទុក្ខលោកសត្វ លោក ។ ព្រះអង្គបានបញ្ជូនព្រះពុទ្ធរូបទាំងនេះ ទៅ លពបុរី , សុវ៌ណ្ណបុរី , រាជបុរី , ពេជ្របុរី , មឿងសិង្ហ (ក្នុងដីសៀមសព្វថ្ងៃនេះ) ។

សិលាចារឹកនៅប្រាសាទព្រះខាន់ មានចំនងដូចសិលាចារឹកនៅ ប្រាសាទ តាព្រហ្ម ដែរ ប៉ុន្តែខ្លីបន្តិច តែជាស្នាដៃរបស់រាជបុត្រ មួយអង្គទៀត នាម " ព្រះវីរកុមារ " [៣] ។ មាតារបស់វីរកុមារ គឺ ព្រះនាង " រាជេន្ទ្រទេវី " ជាអគ្គមហេសីទី ១ ។

សិលាចារឹកនេះ [២] បទដើមនមស្ការ ព្រះរតនត្រ័យ ដូចសិលាចារឹកនៅប្រាសាទ តាព្រហ្មដែរ រៀបរាប់ពីរាជវង្ស សរសើរឫទ្ធិ ព្រះបាទជ័យវរ្ម័នទី ៧ ហើយរៀបរាប់អំពីបញ្ជីវត្ថុ អាហារភោជន ដែលត្រូវប្រើប្រាស់ ក្នុងវត្តព្រះខាន់នេះ ។

សិលាចារឹកនៅប្រាសាទព្រះខាន់ ចែងទុកថា :-

" ព្រះរាជាអង្គណា ( ព្រះបាទជ័យវរ្ម័នទី ៧ ) ច្បាំងមានជ័យ ក្នុងសង្គ្រាម ត្រង់ទីណា ព្រះរាជាអង្គនោះ កសាងបុរីមានឈ្មោះ ថា " ជ យ ស្រី " ត្រង់ទីខាងវស់ឈាមដែលត្រូវស្រក់ទៅនោះ ជាភូមិភាគមានរតនវត្ថុ និង ផ្កាឈូកមាសចាំងរស្មី ធ្វើអោយមានពណ៌ក្រ-

---

[១] G. Coedès, Histoire ancienne des Etats hindouisés d'Extrême Orient, P. 227 -

[២] G. Coedès, la stèle de Prah Khan (BEFEO, XLI, p.255 ) -

www.budinst.gov.kh www.elibraryofcambodia.org

ហម ភ្លឺប្រចាលចន្លាល រហូតមកដល់កាលឥឡូវនេះ ប្រាកដហាក់ដូចនៅយក យោមទីនេះត្រូវនៅលាប " ។

ទ្រង់បានសាងបដិមារាជបិតា ជារូបអង្គពោធិសត្វ លោកេស្វរៈ ថ្វាយនាមថា " ជយវរ្មេស្វរៈ " ដំកល់ទុកក្នុងប្រាសាទជ័យស្រីនេះ ក្នុង គ.ស ១១៩១ ព្រមទាំងបានកសាងព្រះពុទ្ធរូបដទៃជាច្រើនទៀត ។

ព្រះបាទជ័យវរ្ម័នទី ៧ បានកសាងសាលាសំណាក់ តាមផ្លូវពីក្រុងយសោធរបុរៈទៅរាជធានី ចាមចំនួន ៥៧ សាលា ។ ពីក្រុងយសោធរបុរៈ ទៅ ពិមាយ ១៧ សាលា ។ ពីក្រុង យសោធរបុរៈ ទៅក្រុងជយវតី តទៅ ជយសិង្ហវតី តទៅជយវីរវតី តទៅ ជយរាជគិរី តាមផ្លូវ ១៤ សាលា ។ សាលា ១ នៅក្រុងស្រីសូរ្យបព៌ត, ១ នៅក្រុងស្រីវិជយាទិត្យបុរៈ, ១ នៅក្រុងកល្យាណសិទ្ធិកៈ, រួមទាំងអស់ ១២១ សាលា ។ ព្រះពុទ្ធរូបធ្វើពីមាស ប្រាក់ សំរិទ្ធ ថ្ម ដែលទ្រង់បានកសាង នៅគ្រប់ខេត្ត មានចំនួន ២០.៤០០ អង្គ ។

ក្នុងការឧបត្ថម្ភព្រះវិហារ " ជ័យស្រី " នេះ មានបុរស ស្ត្រីរួមទាំងជនជាតិ ចាម វៀត ភូកាម (ភូគាម = ភូមា) និងរួន (Rvam) "១" ផង មានចំនួន ៣០៦.៣៧២ នាក់ ស្រុកចំនួន ១៣.៥០០ ស្រុក អង្គាសជាគ្រឿងពុទ្ធបូជា ៤០០.១២៦ ទារី ។ ព្រះបាទជ័យវរ្ម័នទី ៧ បានបំពេញកុសលឧទ្ទិសបំពោះពុទ្ធសាសនាអស្ចារ្យទីក្រៃលែង មិនចាញ់ព្រះបាទធម្មាសោកមហារាជ (ប្រទេសឥណ្ឌា) នោះទើយ ។

---

"១" ជនជាតិ រួន នេះ មិនដឹងជាជាតិអ្វីទេ លោក សឺដែសយល់ថាប្រហែលជាជាតិ " រាមញ្ញ គឺ មន ឬ ពេគូ " ។

ផ្ទុយពីនេះ ព្រះបាទជ័យវរ្ម័នទី ៧ បានកសាងថ្នល់ធំពីមហានគរ ដល់ប្រទេស ចាម្ប៉ា ដល់ក្រុង ផាងរាង ( បាណ្ឌុរង្គៈ ) ឬក្រុងវិជ័យ ( ខេត្ត ប៊ិញ ឌិញ ) និងទៅកាន់ក្រុង ពិមាយ ( សៀម ) ។ តាមថ្នល់ធំនេះ ទ្រង់បានកសាង "សាលាសំណាក់មានភ្លើង" ចំនួន ១២១ សាលា មួយ ៗ ចំងាយពីគ្នា ប្រហែល ១៥ គីឡូម៉ែត្រ ពីមហានគរទៅ ចាម្ប៉ា មាន ៥៧ សាលា, ពីមហានគរទៅ ពិមាយ ១៧ សាលា, នៅ កន្លែង ផ្សេងទៀត ៤៦ សាលា, នៅភ្នំជីសូរ ១ ព្រមទាំងមន្ទីរពេទ្យ ១០២ អរោគ្យសាលា ផង ។ មានសិលាចារឹកមួយៗ នៅគ្រប់ មន្ទីរពេទ្យ ។ សិលាចារឹកនេះ "១" រៀបរាប់ពីការឧបត្ថម្ភ នៅ ក្នុងមន្ទីរពេទ្យ មានគ្រូពេទ្យ មានគិលានុបដ្ឋាក គិលានុបដ្ឋាយិកា ។ល។ ជនទំណ្ណេះទាំង ឯ នៅក្រោមឱវាទ នៅមន្ទីរពេទ្យបានដូចគ្នា ។ បុគ្គលិកធ្វើការ បាន : គ្រូពេទ្យ ២ នាក់, គ្រូពេទ្យរង ៣ នាក់ ( ប្រុសម្នាក់, ស្រី ២នាក់ ), និធិបាល ( អ្នករក្សាឃ្លាំង ) ២ នាក់, បាចកៈ ( អ្នកគ្រួ ) ២ នាក់, យជ្ញហារី ( អ្នកបូជា ) ២ នាក់, អរោគ្យ សាលាសេវកប្រុស ( គិលានុបដ្ឋាក ) ១៤ នាក់, ស្រី ៨ នាក់ ពីរនាក់ សំរាប់បុកអង្ករ ។ ក្រៅពីនេះ រៀបរាប់ ពីអាហារ ភោជន និង ភេសជ្ជៈ ថែកទៀត ។

ព្រះបាទជ័យវរ្ម័នទី ៧ បានសាងប្រាសាទ បាយ័ន "២" ឧទ្ទិសចំ-ពោះពុទ្ធសាសនា នៅចំកណ្តាលមហានគរ ដើម្បីដំកល់បដិមាព្រះអង្គ ដែលទុកជាតួអង្គ "ពុទ្ធរាជ" ជំនួសអង្គ "ទេវរាជ" ( លិង្គមាស ) ពី បុរាណកាល មិនតែប៉ុណ្ណោះទេ សូម្បីពោធិសត្វ លោកេស្វរៈ សមន្តមុខ ...

---

"១" L.Finot, Inscription sanskrite de Say-Fong, BEFEO, III, P.1

"២" G.Coedès, Histoire ancienne des Etats hindouisés d'Extrême-Orient, P.226 - 227.-

ដែលនៅគ្រប់កំពូលចុងប្រាង្គ បែរព្រះភក្ត្រញញឹម ទៅគ្រប់ទិស ទាំង ៤ ក៏ទុកជាតួអង្គទេវដែរ ។ សិលាចារឹក នៅប្រាសាទបាយ័ន ថ្លែង បញ្ជាក់ថា ប្រាសាទនេះ ជាមជ្ឈមណ្ឌល ការគោរពសកលោក ទេព បូជា នៃ រាជវង្ស និង ខេត្តនានា នៃប្រទេសកម្ពុជា ព្រោះ មហានគរ ដែលមានប្រាការ ១២ គ.ម ជុំវិញ មានភ្នំជាមជ្ឈ-មណ្ឌល ទុកជាតួសកលលោកសន្និវាស ឯប្រាសាទបាយ័ន ទុកជាតួរាជាណា-ចក្រ ( ប្រាង្គកណ្ដាលខ្ពស់ ជារាជធានី ប្រាង្គនៅជុំវិញជាខេត្តនានា ) ជាសញ្ញា នៃការទាក់ទងរវាងមនុស្សលោក និង ទេវលោក នៅ[illegible] បានក្រោមនេះ ។

ទ្រង់បាន បញ្ជូនរាជបុត្រ ទៅសិក្សា វិជ្ជាពុទ្ធសាសនា នៅវត្តមហាវិហារ នាកោះសិរីលង្កា ។ ប្រវត្តិសាស្ត្រ ភូមា និយាយថា " មានសាមណេរ ម ន មួយអង្គឈ្មោះ ឆ ប ត : អាយុ ២០ ឆ្នាំ ចេញទៅរៀននៅកោះសិរីលង្កា ១០ ឆ្នាំ ហើយត្រឡប់មកដល់ប្រទេសភូមាវិញ ពី ពុទ្ធសករាជ ១៧៣៣ ជាមួយនឹង ភិក្ខុឯទៀត ៤ អង្គ មួយអង្គនាម តាមលិន្ទ: ជារាជបុត្រ ស្ដេចនៃប្រទេសកម្ពុជា ។ ភិក្ខុតាមលិន្ទ: នេះប្រហែលជាបុត្រ របស់ព្រះបាទជ័យវរ្ម័នទី ៧ ហើយ ។ ភិក្ខុអង្គនេះ បាននាំពុទ្ធសាសនា ថេរវាទ ចូលមកផ្សាយក្នុងប្រទេស កម្ពុជា យើង ។

ក្រោយរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ ស្ដេចសោយរាជ្យជាតំណវង្ស ត្រឡប់មកកាន់សាសនាព្រាហ្មណ៍វិញ ហើយសាសនាព្រាហ្មណ៍ ក៏រុងរឿងចុងក្រោយបំផុតម្ដងទៀត ។ ឯពុទ្ធសាសនាថេរវាទ ដែលមិនសូវលេចឮ ឈ្មោះ ឬឮសំលេងអស់កាលយូរមកហើយនោះ ក៏រីកចំរើនខ្លាំង

www.budinst.gov.kh www.elibraryofcambodia.org

ណាស់ដែរក្នុងសម័យនោះ ។ លោក ជីវ - តា - ក្វាន់ "១" រាជទូតចិន ដែលបានមកកាន់មហានគរ ក្នុង គ.ស ១២៩៦ បានធ្វើសេចក្តីរាយការណ៍ទុកមកដូច្នេះថា : " ឃើញមានភិក្ខុកោរព្រះកេស ប្រដាប់ ត្រៃចីវរពណ៌លឿង គ្រងបិទចំហៀង ឆ្វេង ទុកស្មាស្តាំទំនេរ ដើរជើងទទេ វិហារប្រក់ក្បឿង ក្នុងវិហារមានតែមួយ គឺ ព្រះ = ព្រះពុទ្ធរូបសក្យមុនី ព្រះពុទ្ធរូបនៅក្នុងវិហារ ធ្វើពីសំរិទ្ធ មិនមានផ្លូងស្គរទេ ឆាន់ត្រីសាច់ មិនឆាន់ស្រាទេ ឆាន់មួយថ្ងៃតែម្តង ក្នុងវត្តអារាម មិនមានផ្ទះធ្វើម្ហូបទេ ភិក្ខុទាំងឡាយនិមន្តបិណ្ឌបាត សូត្រធម៌ គម្ពីរដីកា ចារលើស្លឹករឹត ព្រះរាជាទ្រង់ពិគ្រោះកិច្ចការផង ។ មិនភិក្ខុសង្ឃ មិនមានភិក្ខុនីទេ " ។

ក្នុងរដ្ឋកាលព្រះបាទជ័យវរ្ម័នទី ៧ ប្រទេសកម្ពុជា ហើយចំរើនរុងរឿងណាស់ សមដូចសេចក្តីរាយការណ៍ របស់លោក ជីវ - តា - ក្វាន់ ថា : " កម្ពុជា បរិបូណ៌រុងរឿងណាស់ មហានគរ ( យសោធរបុរៈ ក្នុងរដ្ឋកាលជ័យវរ្ម័នទី ៧ ) កំផែងធំព័ទ្ធជុំវិញនេះ មានគូព័ទ្ធជុំវិញ , មានប្រាការ , មានគោបុរៈ ៥ , មាននាគបង្កាន់ដៃ , មានប្រាសាទមាស ( បាយ័ន ) ជាបង្គោលកណ្តាលនគរ , មានប្រាសាទស្ពាន់ ( បាពួន ) មួយលីទៅខាងជើង ជាព្រះរាជវាំង ។ ខាងក្រៅប្រាការ នៅខាងត្បូង មានប្រាសាទ ភ្នំ ( ភ្នំបាខែង ) , ចេតិយធ្លាប់ ( អង្គរវត្ត ) ។ល។

ព្រះបាទស្រីឥន្ទ្រវរ្ម័ន ឡើងសោយរាជ្យ នៅក្រុងយសោធរបុរៈ ក្នុង គ.ស ១២៩៦ ។ ក្នុងរាជ្យស្តេចអង្គនេះ កើតមានសិលាចារឹក ៖

-----------------------------------------

www.budinst.gov.kh www.elibraryofcambodia.org

ចូលិ មុនដំបូងបង្អស់ ក្នុងប្រវត្តិពុទ្ធសាសនា ថេរវាទ នៅប្រទេសកម្ពុជា យើង "១" :-

(វិសុទ្ធមវិសុទ្ធានំ សុទ្ធិសម្បាបកញ្ចនំ ... )

សេចក្តីប្រែ

"ខ្ញុំសូមនមស្ការ ចំពោះព្រះជិនស្រីធំបរិសុទ្ធ ដែលផ្តល់នូវសេចក្តីបរិសុទ្ធដល់ជនមិនបរិសុទ្ធទាំងឡាយផង ចំពោះព្រះធម៌ផង ចំពោះព្រះសង្ឃផង ដោយសិរសា គឺ ត្បូង សព្វកាលមិនដាច់ ..." ។

ចំណេរឋិរកាលតមក ពុទ្ធសាសនា ថេរវាទ ចំរើនរុងរឿងជាលំដាប់ ៗ

តពីរជ្ជកាលព្រះបាទស្រីន្រ្ទវរ្ម័នមក ក្នុងគ្រិស្តសតវត្សទី ១៥ ប្រទេសកម្ពុជា បានជួបនឹងអន្តរាយ ចុះទន់ខ្សោយទៅបន្តិចម្តងៗ ទើបមកដោយមានចម្បាំងរាំងផលឥតឈប់ឈរ សិលាចារឹកជំនាន់ពីរាជវង្សតៗ មកមិនសូវបាន ប្រវត្តិសាស្ត្រពីបុរាណទាំងប៉ុន្មានដែលមានមកហើយ ក៏អន្តរធានបាត់បង់ទៅវិញតាមកាលវេលា រហូតមកដល់រជ្ជកាលព្រះពញាយ៉ាត ក៏ទ្រង់លះបង់បន្ទាយនគរ (១៤៣១) មកគង់នៅញូសាន (ស្រីសន្ធរ) ហើយតមក ក៏តាំងរាជធានីនៅចតុមុខ គឺក្រុងភ្នំពេញ សព្វថ្ងៃនេះ ៗ

---

១. G.Coedès, La plus ancienne inscription en Pali du Cambodge, Etudes Cambodgiennes ( extrait BEFEO, XXXVI ) P. 14 .

www.budinst.gov.kh www.elibraryofcambodia.org

៥ - ក្រោយសម័យមហានគរ :

ចាប់ពីគ្រិស្តសតវត្សទី ១៥ មកគ្រិស្តសតវត្សទី ២០ ក្រោយសម័យមហានគរមក ពុទ្ធសាសនាថេរវាទ ប្រតិស្ឋានលើដែនដីកម្ពុជា ជាក់ឫសរឹងមាំទៀងទាត់តរៀងមក ឯសាសនាព្រាហ្មណ៍ និង ពុទ្ធសាសនាមហាយាន មិនត្រូវមានសាវ័ក ក៏សាបសូន្យបន្តិចម្តងៗ រហូតដល់អវសាន ប៉ុន្តែឈ្មោះព្រះសិវលិង្គព្រហ្ម នៅសល់តែប្រាសាទថ្មជាដំណែលផងដែរ ពាសពេញប្រទេស ។

ពុទ្ធសាសនាថេរវាទមានលេចធ្លោឡើង ប្រាសាទខ្លះវត្តសាសនាព្រាហ្មណ៍ មកធ្វើជាវត្តពុទ្ធសាសនាវិញ ព្រះពុទ្ធបដិមាត្រូវនៅលើស្ពានព្រះទ្វារទៅ លេចឡើងពុទ្ធរូបផ្សេងៗ ។ វាលវត្តក្បែរនេះ ដែលមានឈ្មោះនៅរលឹកដំបូង វត្តសាសនាព្រាហ្មណ៍ ឈ្មោះនៅជាឈ្មោះវត្តសាសនាព្រាហ្មណ៍ថា អង្គ, តាំង, ក្រាំង, ស្រោង, ភ្នំ ដូចជា អង្គព្រះលិង្គ, តាំងគោក, ក្រាំងស្វាយ, រលាំងចែក, ភ្នំឆាយ ។ ដែលតែក្លាយវត្តសព្វថ្ងៃ ជាវត្តពុទ្ធសាសនា ។ វត្តណាមួយដែលតាំងនៅលើវត្តសាសនាព្រាហ្មណ៍ វត្តនោះមិនមែននៅសល់តែឈ្មោះទេ នៅមានសល់ទាំងស្នាមដែលសាសនាព្រាហ្មណ៍ គឺបាននិកលាស ជាទីសក្ការៈនៅព្រះវិហារទៀតផង ។ ឯទំនៀមទម្លាប់ជឿ ឬ ពិធីផ្សេងៗ ដែលលាយចំរុះជាលទ្ធិសាសនាព្រាហ្មណ៍ និង ពុទ្ធសាសនាមហាយាន ក៏កើតនៅ

www.budinst.gov.kh www.elibraryofcambodia.org

ជាទំនៀមប្រពៃណី ស្រុកទេសជាប់រហូតមកដល់សព្វថ្ងៃនេះ ។

ពីអតីតកាល ប្រជាជនខ្មែរអប់រំកូនចៅតាមប្រពៃណីបុរាណ គឺអោយកូនចៅទៅរៀននៅវត្ត យកវត្តជាសាលារៀន មាន បង្រៀនអក្សរ នព្វន្ត ការរចនា ការស្ថាបនា ច្បាប់សីលធម៌ និង ធម៌ អាថ៌ ពុទ្ធសាសនា ។ កូនខ្មែរដែលបានរៀនសូត្រចេះដឹងគួរសម ហើយ ត្រូវបួសជាសាមណេរ [illegible] ជាភិក្ខុ កើតទៅជាទំនៀមថា កូនប្រុសអាយុ ១២ ឆ្នាំ ត្រូវបួសជាសាមណេរសងគុណមាតា អាយុ ២១ ឆ្នាំ ត្រូវបួស ជាភិក្ខុ សងគុណ បិតា ។

កូនចៅខ្មែរ បើបានបួសជាសាមណេរ ជាភិក្ខុហើយ សឹកមកវិញ ទើបគេរាប់ថាជាមនុស្សពេញអង្គ សឹកមកវិញភ្លាម គេអោយនាម ថា បណ្ឌិត ប្រែថា អ្នកប្រាជ្ញ គេលែងហៅ អា មឹង ដូចពីដើមហើយ ។ បើបានបួសហើយ តែខ្ជិលរៀនសូត្រ ច្បាប់ក្រមខ្មែរបុរាណ ថា " កំជិល អៀនប្រៀន បួសហើយមិនរៀន បន្ទោសថាខ្លៅ " ។

ចាស់ទុំបុរមបុរាណខ្មែរ ធ្លាប់ធ្វើបុណ្យទំនៀមច្រើន ភ្ជាប់នឹង ពុទ្ធសាសនា ដូចជា បុណ្យកាន់បិណ្ឌ បុណ្យស្រង់ព្រះ បុណ្យស្រោច ស្រពមាតាបិតា ចាស់ទុំ បុណ្យបួសនាគ បុណ្យកឋិនទានជាដើម ។ ឯបុណ្យខ្មោច ពិធីអាពាហ៍ពិពាហ៍ បុណ្យ ចូលឆ្នាំ ។ល។ ក៏ចាស់ទុំ

www.budinst.gov.kh www.elibraryofcambodia.org

បញ្ចូល លទ្ធិពុទ្ធសាសនា ជាមង្គលទាំងអស់ ។ ដោយជាតិយើង ចូលចិត្តធ្វើបុណ្យ ដូច្នេះ ហើយបានជាមានពាក្យជនបរទេសថ្កោលទោសយើងថា " ខ្មែរបានជាក្រ មកពីធ្វើបុណ្យច្រើនពេក " ។ ជនជាតិខ្មែរពេញចិត្តនឹងធ្វើបុណ្យយ៉ាងនេះ មកពីរស់ថា " ក្រក៏ក្រចុះ អោយតែមានល្អ គឺមានអរិយទ្រព្យ " ។

www.budinst.gov.kh www.elibraryofcambodia.org

## ពន្យល់ពាក្យ

* ប្រភពផ្សាយពុទ្ធសាសនា ចូលមកប្រទេសកម្ពុជា :

១_ សង្គាយនា : ន. ៖ ការប្រជុំផ្ទៀងធម៌ ឬ ចង្វាប់អោ ត្រឹមត្រូវពេញគ្រប់តាមបែបដើម , ការប្រជុំផ្ទៀងព្រះត្រៃបិដក ពុទ្ធវចនៈ អោយត្រឹមត្រូវ មិនអោយឃ្លៀងឃ្លាត ចាកបែបដើម : បឋមសង្គាយនា , ទុតិយសង្គាយនា , តតិយសង្គាយនា ។ សូមឲ្យនិមន្ត ធម្មកថិក ២ ឬ ៣ រូប ទេសនាចោទឆ្លើយយ៉ាងសង្ខេប មាន តំណាលរឿងសង្គាយនា ពីព្រេងនាយតាមពុទ្ធសាសនប្រវត្តិ ដែលគេហៅ សង្គាយនាដែរ ៖ និមន្តលោកទេសនា សង្គាយនា , សង្គាយនាបង្ហើយបុណ្យៗ

∴ សម័យនគរភ្នំ :

២_ លី : ៥៧៦ ម៉ែត្រ _ ពីប្រទេស ចាម្ប៉ា មកនគរភ្នំមាន ចំងាយ ១០០០ លី គឺ ស្មើនឹង ៥៧០ គីឡូម៉ែត្រ ។

៣_ មហេស្វរៈ ឬ មហិស្សរៈ (ន) ៖ ព្រះឥសូរ

៤_ អវលោកិតេស្វរៈ (ន)៖ នាមនៃពោធិសត្វ ដែលពួក ពុទ្ធសាសនិក ខាងមហាយានសន្មត ដោយឧប្បត្តិក ថាជាទេវតាវិសេស មួយអង្គ ជាអ្នកពិនិត្យមើលទុក្ខទុក្ខជាដើម របស់សត្វលោក ព្រមទាំង ចាំថែរក្សា សត្វលោកផង ( ទេវបដ្ឋានឹងមហាព្រហ្ម ឬ វិស្ណុ របស់ពួក

www.budinst.gov.kh www.elibraryofcambodia.org

ព្រាហ្មណ៍ ) ។ នេះច្រើនធ្វើមុខ ៤ នៅកំពូលប្រាសាទ ឬ កំពូល ចេតិយ សំគាល់ថាជាព្រះឥន្រ្ទ ឬ អវលោកិតេស្វរៈ ដើម្បីរក្សាការពារ មនុស្សលោកឲ្យចៀសផុតពីគ្រោះថ្នាក់ទាំងឡាយ ប៉ុន្តែនៅក្នុងលទ្ធិព្រាហ្មណ៍ថា មុខព្រហ្ម ។ ហៅ អវលោកេស្វរៈ ក៏បាន ឬ លោកេស្វរៈ ក៏បាន ។ ។

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org